សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រាតិភោគនៅធនាគារ អេស៊ីលីដា ភីអិលស៊ី

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហេង ថៃផេង**

**សាំង កក្កដា**

សាស្ត្រាចារ្យណែនាំ

លោក **ជិន វណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហេង ថៃផេង** និង ខ្ញុំបាទឈ្មោះ **សាំង ភក្កដា** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី ១៤ ក្នុងឆ្នាំសិក្សា២០១០-២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានកិត្តិយសសូមសម្តែងនូវការថ្លែងអំណរគុណ និង ការដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះលោក អ្នកមានគុណ

លោកឪពុក **ហេង ហម** និង អ្នកម្តាយ **តាំង ឡូចនី**

លោកឪពុក **អ៊ូ ម៉ុនឈួត** និង អ្នកម្តាយ **ផេង សុគ្គា**

ដែលលោកឪពុក អ្នកម្តាយ បានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌។ ជាងនេះទៅលោកឪពុក អ្នកម្តាយបានអប់រំ និងបានផ្តត់ផ្គង់នូវ ប្រាក់កាស់ ឲ្យកូនបានសិក្សារៀនសូត្រតាំងពីថ្នាក់មតេយ្យសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា ដើម្បីកូនមានចំនេះចេះដឹង សម្រាប់ជាប្រយោជន៍នាថ្ងៃអនាគត។ លោកក៏បានអប់រំទូន្មានកូនជារឿយៗ ឲ្យកសាងខ្លួនឲ្យមានប្រយោជន៍សម្រាប់ខ្លួនឯង សម្រាប់គ្រួសារ និងសង្គមជាតិ និងជៀសវាងនូវអំពើអាក្រក់ទាំងឡាយក្នុងសង្គម។ យើងខ្ញុំសូមបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកឲ្យតាមជួយថែរក្សា និងគាំពារលោកអ្នកមានគុណឲ្យមានសុខភាពល្អបរិបូរណ៍ ដើម្បីកូនបានតបស្នងសងគុណលោកអ្នកមានគុណ ប្រកបដោយការដឹងគុណ។

សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀន ណែនាំផ្តល់ការអប់រំដល់យើងខ្ញុំ និងបុគ្គលិករបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានផ្តល់បរិយាកាស និងភាពងាយស្រួលសម្រាប់ការសិក្សានៅទីនេះ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ លោកសាស្ត្រាចារ្យ **ខិន វណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យទទួលបន្ទុកណែនាំសារណានេះ ដោយបានលះបងនូវពេលវេលាដ៏មានតម្លៃ និងកំលាំងកាយចិត្ត ក្នុងការពន្យល់ណែនាំ និងកែសម្រួលចំពោះសារណានេះ រហូតទទួលបាននូវលទ្ធផលជោគជ័យ។ ជាចុងក្រោយយើងខ្ញុំក៏ថ្លែងនូវអំណរគុណដល់ សិស្សច្បង និងមិត្តរួមថ្នាក់ដែលបានជួយ ផ្តល់នូវឯកសារ និងគំនិតល្អៗ ដើម្បីសារណានេះមានភាពល្អប្រសើរ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់បានខិតខំសិក្សាអស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ដោយទទួលបាននូវលទ្ធផលល្អក្នុងការសិក្សា ទើបសាកលវិទ្យាល័យបានសម្រេច ឲ្យយើងខ្ញុំមានឱកាសសរសេរសារណា ដើម្បីបញ្ជាក់ពីសមត្ថភាព ចំនេះដឹងក្នុងការស្រាវជ្រាវ។

ដោយផ្អែកលើតម្រូវការរបស់សាកលវិទ្យាល័យ យើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយ **ប្រាតិភោគ នៅធនាគារអេស៊ីលីដា ភីអិលស៊ី** ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ប្រធានបទនេះតម្រូវឲ្យមានការសិក្សាស្រាវជ្រាវជាខ្លាំងនូវ នីតិវិធីច្បាប់ និងការអនុវត្តនូវនីតិវិធីជាក់ស្តែងនៅក្នុង គ្រឹះស្ថានហិរញ្ញវត្ថុ( អេស៊ីលីដា ភីអិលស៊ី ) ក្នុងការដាក់ប្រាតិភោគ( បញ្ចាំហ៊ីប៉ូតែក ) ដែលប្រជាពលរដ្ឋកម្ពុជាមិនសូវបានស្គាល់ និងអនុវត្តឲ្យបានទូលំទូលាយនៅឡើយ។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីនីតិវិធី និងគោលការណ៍មួយចំនួនទាក់ទងនឹងប្រាតិភោគ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងអាចចូលរួមចំនែកក្នុងការសិក្សាស្វែងយល់ពីរបស់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ សម្រាប់ធ្វើការសិក្សាស្វែងយល់បន្ថែមអំពីប្រធានបទនេះ។ តែទោះជាយ៉ាងណា ដោយយោងតាមកម្រឹតសិក្សា និងពេលវេលានៃការ ស្រាវជ្រាវមានកំណត់ ដូច្នេះហើយសារណានេះអាចមានកំហុសឆ្គងខ្លះៗជាក់ជាមិនខាន។ យើងខ្ញុំរីករាយនឹងទទួលនូវការរិះគន់ក្នុងន័យស្ថាបនាដោយសេចក្តីសោមនស្សនិងអំណរបំផុត ពីសំណាក់សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បីជួយកែលម្អ នឹងធ្វើឲ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

ជាចុងក្រោយ សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវដែលបានយកចិត្តទុកដាក់អានសារណានេះ និងសូមគោរពជូនពរដល់អ្នកអានទាំងអស់ឲ្យបានជួបតែសំណាងល្អ សុខភាពល្អបរិបូរណ៍ និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ចការទាំងអស់ជានិរន្តរ៍តរៀងទៅ៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូក ១ ការបញ្ចាំ**

**១.១. សញ្ញាណទូទៅទាក់ទងការបញ្ចាំ** ........................................ ៣

១.១.១. សញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ ........................................ ៣

១.១.១.១. និយមន័យ សិទ្ធិលើការបញ្ចាំ ........................................ ៣

១.១.១.២. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា ........................................ ៤

១.១.២. ការបង្កើតកិច្ចសន្យាបញ្ចាំ ........................................ ៤

១.១.២.១. លក្ខខណ្ឌសុពលភាព ........................................ ៥

១.១.២.២. លក្ខខណ្ឌជំទាស់នឹងតតិយជន ........................................ ៦

១.១.៣. កម្មវត្ថុនៃការបញ្ចាំ ........................................ ៧

១.១.៣.១. ការបញ្ចាំចលនវត្ថុ ........................................ ៧

១.១.៣.២. ការបញ្ចាំអចលនវត្ថុ ........................................ ៨

១.១.៣.៣. ការបញ្ចាំសិទ្ធិ ........................................ ៨

**១.២. ប្រតិបត្តិការបញ្ចាំនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី** ........................................ ៩

១.២.១. ការព្រមព្រៀងលើសេវា ........................................ ១០

១.២.១.១. ប្រភេទសេវាឥណទាន នៅធនាគារ អេស៊ីលីដា ........................................ ១០

ក. ឥណទានខ្នាតតូចបំផុត ........................................ ១០

ខ. ឥណទានខ្នាតតូច ........................................ ១១

គ. ឥណទានខ្នាតមធ្យម ........................................ ១២

ឃ. ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ........................................ ១៣

ង. ឥណទានវិបារូបរ៍ ........................................ ១៤

ច. ឥណទានវិបារូបរ៍សម្រាប់អតិថិជនបញ្ញើ-សន្សំ ........................................ ១៦

ឆ. ឥណទានសម្រាប់ទុនបង្វិល ........ ១៦
ជ. កម្រិតបន្ទាត់ឥណទាន ........ ១៧
ឈ. ឥណទានគេហដ្ឋាន ........ ១៩
ញ. ឥណទានរថយន្ត ........ ២០
ប. ឥណទានកែលំអលំនៅឋាន ........ ២២
ផ. ឥណទានម៉ូតូ ........ ២៣
១.២.១.២. អត្រាការប្រាក់ ........ ២៤
ក. ឥណទានជាប្រាក់រៀល ........ ២៤
ខ. ឥណទានជាប្រាក់បាត ........ ២៥
គ. ឥណទានជាប្រាក់ដុល្លារអាមេរិក ........ ២៥
១.២.២. លក្ខខណ្ឌដើម្បីទទួលបានឥណទាន ........ ២៦
១.២.២.១. ឥណទានគេហដ្ឋាន ........ ២៦
ក. និយមន័យ ........ ២៦
ខ. ប្រភេទរូបិយប័ណ្ណ ........ ២៦
គ. កំណត់ទំហំឥណទាន ........ ២៦
ឃ. រយៈពេលឥណទាន ........ ២៦
ចៈ. ការបើកប្រាក់កម្ចី ........ ២៧
១.២.២.១. ឥណទានរថយន្ត និង ម៉ូតូ ........ ២៨
ក. និយមន័យ ........ ២៨
ខ. លក្ខណៈពិសេស ........ ២៩
គ. ទំហំឥណទាន ........ ៣០
ឃ. កំរិតនៃប្រាក់សំណាង ........ ៣០
១.២.៣. ការសងត្រឡប់មកវិញនៃឥណទាន ........ ៣១
១.២.៣.១. របៀបសងប្រាក់ ........ ៣១
១.២.៣.២. ការសងត្រឡប់មកវិញ ........ ៣១

១.២.៤. ការខកខានសង និងការពិន័យ ........................................ ៣២
១.២.៤.១. ការខកខានសង ........................................ ៣២
ក. ការខកខានសងកម្រិតស្រាល ........................................ ៣២
ខ. ការខកខានសងធ្ងន់ធ្ងរ ........................................ ៣២
១.២.៤.២. ការពិន័យ ........................................ ៣៣
ក. ពិន័យ ........................................ ៣៣
ខ. ការលុបចោលប្រាក់ពិន័យ ........................................ ៣៣

## ជំពូក២ ហ៊ីប៉ូតែក

**២.១.សញ្ញាណទូទៅទាក់ទងហ៊ីប៉ូតែក** ........................................ ៣៤
**២.២.ការបង្កើតហ៊ីប៉ូតែក** ........................................ ៣៤
២.២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី ........................................ ៣៥
២.២.១.១. ការព្រមព្រៀង ........................................ ៣៥
២.២.១.២. សមត្ថភាពនៃគូភាគី ........................................ ៣៥
២.២.១.៣. កម្មវត្ថុ ........................................ ៣៧
២.២.១.៣.១. អចលនវត្ថុ ........................................ ៣៨
២.២.១.៣.២. សិទ្ធិជួលអចិន្ត្រៃយ៍ ........................................ ៣៨
២.២.១.៣.៣. ផលុបភោគ ........................................ ៣៨
២.២.២. លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក ........................................ ៣៩
**២.៣. អានុភាពនៃហ៊ីប៉ូតែក** ........................................ ៤០
២.៣.១. ទំហំនៃអានុភាពហ៊ីប៉ូតែក ........................................ ៤០
២.៣.២. ឧបាទេសកម្ម ........................................ ៤១
២.៣.៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ ........................................ ៤១
២.៣.៤. លំដាប់នៃហ៊ីប៉ូតែក ........................................ ៤១
២.៣.៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........................................ ៤២
**២.៤. ការអនុវត្ត និងការចាត់ចែងហ៊ីប៉ូតែក** ........................................ ៤៣

២.៤.១. ការអនុវត្តហ៊ីប៉ូតែក ......................................................... ៤៣
២.៤.២. ការចាត់ចែងហ៊ីប៉ូតែក ......................................................... ៤៤
**២.៥. ការរលត់នៃហ៊ីប៉ូតែក** ......................................................... ៤៥
២.៥.១. ការរលត់ដោយការទាមទារ ......................................................... ៤៥
២.៥.១.១. ការបំពេញនូវកាតព្វកិច្ចរបស់កូនបំណុល ......................................................... ៤៥
២.៥.១.២. ការសងដោយថ្លៃលក់របស់តតិយជន ......................................................... ៤៥
២.៥.២. ការរលត់ដោយអាជ្ញាយុកាល ......................................................... ៤៦
**២.៦.ការបង្កើតហ៊ីប៉ូតែកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី** ......................................................... ៤៦
២.៦.១. ភាគីទទួលយកការបង្កើតហ៊ីប៉ូតែក ......................................................... ៤៦
២.៦.២. ភាគីបង្កើតហ៊ីប៉ូតែក ......................................................... ៤៧
២.៦.៣. ការវាយតម្លៃឥណទាន ......................................................... ៤៨
២.៦.៤. កម្មវត្ថុនៃហ៊ីប៉ូតែក ......................................................... ៤៩
២.៦.៥. ហ៊ីប៉ូតែកតូប ឬ ស្តង់ ......................................................... ៥០
**សេចក្តីសន្និដ្ឋាន** ......................................................... ៥១
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សេដ្ឋកិច្ចពិតជាវិស័យមួយមានសារៈសំខាន់ ដើម្បីឲ្យប្រទេសមួយត្រូវបានវាយតម្លៃថាជាប្រទេសអភិវឌ្ឍ រីកចម្រើន ឬ កំពុងអភិវឌ្ឍ ឬ តតិយលោក។ យ៉ាងណាមិញ ប្រទេសកម្ពុជា ក៏កំពុងខិតខំជម្រុញ ពង្រីកវិស័យសេដ្ឋកិច្ចនេះផងដែរតាមការកៀងគរអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសដើម្បីមកបណ្តាក់ទុន លើគ្រប់វិស័យ ។ ជាពិសេស បើយើងក្រឡេកមើល វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ វិស័យនេះចាប់មានសន្ទុះគួរអោយកត់សម្គាល់ ។

តាមរយៈនៃការធ្វើហិរញ្ញប្បទាន ធនាគារអេស៊ីលីដា ភីអិលស៊ីក៏បានចូលរួមចំណែក និងដើរតួយ៉ាងសកម្មលើការផ្តល់ឥណទានដល់អតិថិជន ទូទាំងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអេស៊ីលីដា ភីអិលស៊ីបានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅក្នុងអំឡុងឆ្នាំ ១៩៩៣ ក្រោមរូបភាពជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលទទួលជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ដើម្បីផ្តល់នូវប្រាក់កម្ចីដល់ប្រជាពលរដ្ឋ ក្នុងអត្រាការប្រាក់ទាប បន្ទាប់មកបានធ្វើការអភិវឌ្ឍខ្លួនរហូតក្លាយជាធនាគារពាណិជ្ជដ៏មានសក្តានុពលមួយដូចសព្វថ្ងៃនេះដែលមានតំបន់ប្រតិបត្តិការ របស់ខ្លួនពីថ្នាក់ខេត្តក្រុងរហូតដល់មូលដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋទូទាំងម្ភៃបួនខេត្ត រាជធានី។ លើសពីនេះទៅទៀតធនាគារអេស៊ីលីដា ក៏បានបង្កើតសាខារបស់ខ្លួនទៅកាន់ប្រទេសមីយ៉ាន់ម៉ា និង ប្រទេសឡាវផងដែរ។

បច្ចុប្បន្ន ធនាគារអេស៊ីលីដា ភីអិលស៊ីមានបម្រើសេវាកម្មជាច្រើន រួមទាំងសេវាឥណទានសម្រាប់តម្រូវការក្នុងការប្រើប្រាស់របស់អតិថិជន។ សេវាឥណទានរបស់ធនាគារ អេស៊ីលីដា មានការកើនឡើងជាលំដាប់ ដោយសារតែមានការទុកចិត្តចំពោះសុវត្ថិភាពទ្រព្យធានា និងនីតិវិធី ដើម្បីទទួលបានឥណទាន។ ធនាគារអេស៊ីលីដាក៏បានបង្កើតឲ្យមានយន្តការធានាទ្រព្យរបស់ខ្លួន តាមរយៈការដាក់ទ្រព្យសម្បត្តិរបស់អតិថិជន ដែលរួមមាន ការដាក់បញ្ចាំចលនវត្ថុ និងអចលនវត្ថុ ការដាក់ហ៊ីប៉ូតែក ទៅលើអចលនវត្ថុ ដូចជា ដីធ្លី គេហដ្ឋាន និងតូប ឬ ស្តង់អាជីវកម្ម ជាដើម។

ជាមួយគ្នានេះផងដែរ រដ្ឋាភិបាលបានអនុម័ត ច្បាប់ជាច្រើនដែលទាក់ទងនឹងការធ្វើជំនួញដើម្បីជាផលប្រយោជន៍ និងទំនុកចិត្ត សុវត្ថិភាពទាំងសងខាង ដល់ប្រជាពលរដ្ឋ និងវិនិយោគិន ក៏ដូចជាគ្រឹះស្ថានឯកជនដែលបាននឹងកំពុងធ្វើសកម្មភាពជំនួញក្នុងប្រទេសកម្ពុជា។ បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធរួមមានៈ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធី

ព្រហ្មទណ្ឌ ច្បាប់ភូមិបាល ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងប្រកាសផ្សេងៗរបស់ក្រសួងពាក់ព័ន្ធផងដែរ។

ដោយមើលឃើញពីសក្តានុពលនៃវិស័យធនាគារ និងការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាឥណទានរបស់ធនាគារ ដើម្បីពង្រីកអាជីវកម្ម ដូច្នេះ ក្រុមយើងខ្ញុំបានសម្រេចចងក្រងជាសារណានេះឡើងក្រោមប្រធានបទ **ប្រាតិភោគ នៅធនាគារអេស៊ីលីដា ភីអិលស៊ី** ដោយក្រុមយើងខ្ញុំផ្តោតសំខាន់ លើការបញ្ចាំ និងហ៊ីប៉ូតែក។

ដើម្បីងាយស្រួលក្នុងការអធិប្បាយឲ្យកាន់តែច្បាស់អំពីប្រធានបទស្តីពី **ប្រាតិភោគ នៅធនាគារអេស៊ីលីដា ភីអិលស៊ី** យើងនឹងធ្វើការបកស្រាយ ការបញ្ចាំដោយមានកាធានា នៅក្នុងជំពូក ១ និងហ៊ីប៉ូតែក នៅក្នុងជំពូក២។

# ជំពូក ១ ការបញ្ចាំ

ការបញ្ចាំ គឺជាកិច្ចសន្យាមួយដែលធ្វើឡើងរវាងកូនបំណុល និងម្ចាស់បំណុល ដើម្បីស្វែងរកផលប្រយោជន៍របស់ខ្លួនពីកិច្ចសន្យានេះ ហើយការបញ្ចាំនេះត្រូវធ្វើឡើងដោយកូនបំណុលត្រូវប្រគល់វត្ថុនៃការបញ្ចាំទៅឲ្យទៅឲ្យម្ចាស់បំណុល ហើយម្ចាស់ត្រូវប្រគល់ប្រាក់ទៅឲ្យកូនបំណុលវិញទៅតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យាបញ្ចាំនោះ។

## ១.១. សញ្ញាណទូទៅទាក់ទងការបញ្ចាំ

នៅក្នុងសញ្ញាណទូទៅទាក់ទងសិទ្ធិលើការបញ្ចាំនេះយើងខ្ញុំ នឹងធ្វើការបកស្រាយនូវចំនុចបីធំៗគឺ សញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ(១.១.១) កាបង្កើតកិច្ចសន្យាការបញ្ចាំ(១.១.២) និងកម្មវត្ថុនៃការបញ្ចាំ(១.១.៣)។

### ១.១.១. សញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ

នៅក្នុងសញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំនេះផងដែរ មានចំនុច ពីរ យកមកបកស្រាយគឺ និយមន័យសិទ្ធិលើការបញ្ចាំ(១.១.១.១) និងទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា(១.១.១.២)។

#### ១.១.១.១. និយមន័យ សិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុ ដែលបានទទួលពីកូនបំណុល ឬ តតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។[1] ក្នុងមាត្រានេះមានន័យថា ការបញ្ចាំគឺជាប្រភេទនៃកិច្ចសន្យាប្រតិភោគមួយប្រភេទ ដែលមានកូនបំណុល និងម្ចាស់បំណុល ហើយកិច្ចសន្យានេះអាចកើតឡើង នៅពេលដែលកូនបំណុល ឬ តតិយជន(អ្នកយកទ្រព្យទៅបញ្ចាំ) បានយកទ្រព្យរបស់ខ្លួនទៅបញ្ចាំ និងម្ចាស់បំណុល(អ្នកទទួលការបញ្ចាំ) ដើម្បីធានានូវការសងបំណុលរបស់ខ្លួនទៅឲ្យម្ចាស់បំណុលវិញ ហើយម្ចាស់បំណុលកាន់កាប់វត្ថុនោះរហូតដល់ពេលចប់កិច្ចសន្យា។ នៅក្នុងករណីដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងនោះ

[1] មាត្រា ៨១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទេ ម្ចាស់សិទ្ធលើការបញ្ចាំ អាចទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីតម្លៃថ្នូរនៃវត្ថុបញ្ចាំនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

### ១.១.១.២. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា

ជាគោលការណ៍ ប្រសិនបើមានភាពីម្ខាង នៃកិច្ចសន្យាបានរំលោភបំពាន មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នោះនាំឲ្យមានការខាតបង់ដល់ភាគីម្ខាងទៀតជាមិនខាន។ ដូច្នេះហើយ ទើបច្បាប់បានបញ្ញត្តិការការពារដល់ភាគីរងគ្រោះដោយការរំលោភបំពាននោះ ហើយភាពីរងគ្រោះមានសិទ្ធិប្តឹងទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ ឬ ស្នើសុំឲ្យសងសំណងនៃការខូចខាត និងស្នើសុំរំលាយកិច្ចសន្យាជាដើម ហើយបញ្ញត្តិទាំងនេះមានចែងនៅក្នុងគន្ថីទី៤ ជំពូកទី៤ ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា។ ប្រសិនបើកូនបំណុលនូវតែមិនអនុវត្ត ឬ ពុំមានលទ្ធភាពក្នុងការអនុវត្ត ភាគីរងគ្រោះអាចស្នើសុំឲ្យតុលាការ យកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាមកលក់ ដើម្បីយកប្រាក់មកទូទាត់សងបំណុល និងសង់ការខូចខាត មកឲ្យម្ចាស់បំណុលវិញ។

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា គឺជាទំហំនៃសិទ្ធិដែលម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្តឹងទាមទារសំណងនៃការខូចខាត ពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដែលបានបំពានលើកិច្ចសន្យា ដូចជាសិទ្ធិលើការបញ្ចាំ ត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសង ក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ។[2]

## ១.១.២. ការបង្កើតកិច្ចសន្យាបញ្ចាំ

ប្រជាជនទូទៅមិនទាន់បានយល់ច្បាស់នូវឡើយ អំពីការបង្កើតកិច្ចសន្យាបញ្ចាំឲ្យមានសុពលភាព ឲ្យស្របទៅតាមច្បាប់នោះទេដោយពួកគេមួយចំនួនបានធ្វើការបញ្ចាំដោយគ្មាកិច្ចសន្យាច្បាស់លាស់ ឬ សន្យាដោយពាក្យសម្តី មិនមានអ្វីជាសំអាងទៀត ជាហេតុដែលធ្វើឲ្យមានការឆបោកពីសំណាក់ជនខិលខូចមួយចំនួន។ នៅក្នុងចំនុច ការបង្កើតកិច្ចសន្យាបញ្ចាំនេះផងដែរ យើងបានលើយក ចំនុចពីរ យកមកបកស្រាយ លក្ខខណ្ឌសុពលភាព(១.១.២.១) និងលក្ខខណ្ឌជំទាស់នឹងតតិយជន(១.១.២.២)។

[2] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.១.២.១. លក្ខខណ្ឌសុពលភាព

ដើម្បីបង្កើតកិច្ចសន្យាបញ្ចាំបាន ត្រូវគោរពតាមលក្ខខណ្ឌដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាផ្សេងៗផងដែរ ដូចជាមានការព្រមព្រៀងពីភាគីទាំងសងខាង ដោយសេរីមិនមានការបង្ខិតបង្ខំឡើយ ហើយមានភាគី ម្ខាងជាម្ចាស់បំណុល "ម្ចាស់សិទ្ធិលើការបញ្ចាំ" និងភាគីម្ខាងទៀតជាកូនបំណុល "អ្នកបង្កើតសិទ្ធិលើការបញ្ចាំ"។ ដើម្បីឲ្យកិច្ចសន្យាមានអានុភាព គឺទាល់តែសំណើ និងស្វីការត្រូវគ្នា។[3] បើយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៣៣៧ បានឲ្យនិយម័យថា សំណើគឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយ នឹងចំណាងគតិយុត្ត ក្នុងករណី ដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ ចំនែកឯ ស្វីការ គឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ហើយការបង្កើតកិច្ចសន្យាដើម្បីឲ្យមានសុពលភាពទាល់តែភាគី ដែលបង្កើតកិច្ចសន្យាទាំងពីរភាគី គឺជាជនដែលមានសមត្ថភាពពេញលេញ ក្នុងការបង្កើតកិច្ចសន្យាឲ្យស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ គឺសំដៅទៅដល់ជនទាំងឡាយណា ក្រៅពីជននៅក្រោមអាណាព្យាបាលទូទៅ និងក្រៅជននៅក្រោមហិតូបត្ថម្ភ និងក្រៅពីអនីតិជន លើកលែងតែអនីតិជនដែលទទួលបាននូវអត្តាធីនភាព។

នៅពេលបង្កើតកិច្ចសន្យាបញ្ចាំ ភាគីត្រូវកំណត់ពីចំនួនទឹកប្រាក់ និងចំនួនការប្រាក់ឲ្យបានច្បាស់ និងប្រភេទនៃវត្ថុបញ្ចាំផងដែរ។ លើសពីនេះទៅទៀត នៅកិច្ចសន្យាបញ្ចាំត្រូចកំណត់ពេលវេលាឲ្យបានច្បាស់លាស់ ហើយការបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ និងការបញ្ចាំសិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានកំណត់ពីថិរវេលាច្បាស់លាស់នោះទេ លើកលែងតែការបញ្ចាំអចលនវត្ថុប៉ុណ្ណោះដែលបានចែងថា អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ កិច្ចសន្យានោះត្រូវបន្ថយអំឡុងពេលមកត្រឹម ៥ (ប្រាំ) ឆ្នាំវិញ។ ហើយកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ប៉ុន្តែអំឡុងពេលនៃការបន្តនោះមិនឲ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្ត។[4]

---

[3] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[4] មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការបង្កើតសិទ្ធិលើការបញ្ចាំកើតឡើងនៅពេលដែលកូនបំណុល ឬ តតិយជនដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ។[5] មានន័យថា សិទ្ធិលើការបញ្ចាំមានអានុភាពនៅពេលដែលកូនបំណុលប្រគល់វត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់បំណុលកាន់កាប់ តែបើមិនបានប្រគល់វត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់បំណុលទេនោះ កិច្ចសន្យាបញ្ចាំនេះមិនមានអានុភាពទេ។ ហើយនៅក្នុងក្រមរដ្ឋប្បវេណីថ្មីក៏មិនបានបញ្ជាក់ឲ្យច្បាស់ពីប្រភេទនៃកិច្ចសន្យាបញ្ចាំនោះដែរ ថាត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬ មិនលាយលក្ខណ៍អក្សរ ឬមួយលិខិតយថាភូត ឬ យ៉ាងណានោះទេ គឺគ្រាន់តែតម្រូវឲ្យមានការយល់ព្រមពីភាគីទាំងសងខាងប៉ុណ្ណោះ។

### ១.១.២.២. លក្ខខណ្ឌជំទាស់នឹងតតិយជន

លក្ខខណ្ឌជំទាស់នឹងតតិយជន គឺជាលក្ខខណ្ឌសំខាន់មួយដែលម្ចាស់បំណុលត្រូវគោរពតាម ដើម្បីការពារផលប្រយោជន៍របស់ខ្លួនពីការឈ្លានពានរបស់តតិយជនដែលមានបំណងមិនល្អ។ ហើយការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីនោះទេ គឺគ្រាន់តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ (កូនបំណុល) ត្រូវប្រគល់វត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល) កាន់កាប់ដើម្បីធានាលើបំណុលរបស់ខ្លួន។ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ គឺម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំសិទ្ធិលើការបញ្ចាំនោះ ចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ។[6] មានន័យថា ប្រសិនបើម្ចាស់បំណុលមិនបានកាន់កាប់វត្ថុបញ្ចាំជានិរន្តរ៍នៅក្នុងដៃរបស់ខ្លួនទេនោះ ម្ចាស់បំណុលមិនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹងតតិយជនបានឡើយ។

ការបញ្ចាំអចលនវត្ថុ ច្បាប់តម្រូវឲ្យយកបទបញ្ញត្តិស្ដីពីហ៊ីប៉ូតែកមកអនុវត្ត ហើយដើម្បីបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមួយ ដែលអាចយកទៅជំទាស់នឹងតតិយជនបានលុះត្រាតែកិច្ចសន្យានោះធ្វើជាលិខិតយថាភូត និងត្រូវចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លី ឬនៅអង្គភាពសុរិយោដី។[7]

[5] មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[7] មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.១.៣. កម្មវត្ថុនៃការបញ្ចាំ

បើនិយាយពី កម្មវត្ថុ គឺមានន័យថា ជាគោលបំណងនៃកិច្ចសន្យាមួយ ដែលបានបង្កើតឡើងដោយឆន្ទៈរបស់គូភាពីទាំងសងខាង។ ឯនិយមន័យនៃពាក្យថា វត្ថុ សំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង។[8] បើយើងក្រឡេកមើលទៅក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ មាត្រា ៨១៦ ស្តីពីសិទ្ធិលើការបញ្ចាំ បានបញ្ជាក់ថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់លើវត្ថុដែលទទួលបានពីកូនបំណុល។ នៅក្នុងមាត្រានេះ ពាក្យថា "វត្ថុ" គឺត្រូវបានប្រើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ប៉ុន្តែតាមរយៈមាត្រាខាងលើនេះមិនបានបញ្ជាក់អត្ថន័យឲ្យស៊ីជម្រៅនិងច្បាស់លាស់នោះទេ។ ម្យ៉ាងវិញទៀត ទោះបីជាការប្រើពាក្យថា "វត្ថុ" នៅក្នុងមាត្រា ៨១៦ ខាងលើក៏ដោយ ក៏ពុំមានន័យថា សិទ្ធិ ពុំអាចក្លាយជាកម្មវត្ថុនៃការបញ្ចាំបាននោះឡើយ។

បើយោងតាមការអនុវត្ត និងកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំយើងអាចគាត់សំគាល់ថាមាន ៣ ធំៗ គឺ ចលនវត្ថុ (មាត្រា ៨២៩) អចលនវត្ថុ (មាត្រា ៨៣៤) និងសិទ្ធិលើទ្រព្យសម្បត្តិ ឬ ការបញ្ចាំសិទ្ធិ (មាត្រា ៨៤០)។

#### ១.១.៣.១. ការបញ្ចាំចលនវត្ថុ

ការបញ្ចាំចលនវត្ថុ មានចែងនៅក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ក្នុងជំពូកទី៤ ផ្នែកទី២ ចាប់ពីមាត្រា ៨២៩ ដល់ ៨៣៣។ ចំណែកពាក្យថា ចលនវត្ថុ មានន័យថាជាវត្ថុ ឬ ជាទ្រព្យទាំងឡាយណាដែល អាចលើកដាក់បាន កម្រើកបាន និងអាចផ្លាស់ប្តូរទីកន្លែងបាន មានដូចជា ឡាន ម៉ូតូ គ្រឿងអលង្ការជាដើម នេះបើតាមសេចក្តីពន្យល់ នៅក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។ ចំណែកក្នុងក្រមរដ្ឋប្បវេណីវិញបានចែងថា ចលនវត្ថុ គឺសំដៅទៅដល់វត្ថុក្រៅពីអចលនវត្ថុ។[9] ហើយជាទូទៅកម្មវត្ថុក្នុងកិច្ចសន្យា បញ្ចាំចលនវត្ថុ វាគឺជាវត្ថុដែលកូនបំណុលយកទៅដាក់បញ្ចាំ ដើម្បីធានាលើបំណុលរបស់ខ្លួន ហើយចលនវត្ថុនោះ ត្រូវជាកម្មសិទ្ធិរបស់កូនបំណុល ប្រសិនបើកូនបំណុលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ ជាកម្មសិទ្ធិរបស់តតិយជនប្រសិនបើតតិយជននោះជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាបំណុលអ្នកដទៃ ហើយចលនវត្ថុនោះត្រូវតែជាចលនវត្ថុ ដែលអាចរឹបអូសបាន។

[8] មាត្រា ១១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ១២០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧

ឧទាហរណ៍ លោក **ក** បានយក ម៉ូតូ ដែលជាកម្មសិទ្ធិរបស់ខ្លួនទៅដាក់បញ្ចាំ លោក **ខ** ដើម្បីធានាលើបំណុលរបស់ខ្លួនចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិក។

**១.១.៣.២. ការបញ្ចាំអចលនវត្ថុ**

ពាក្យថា អចលនវត្ថុ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ គឺបានសំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដី ហើមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដីចំការ ដីស្រែ ដំណាំ រុក្ខជាតិជាអាទ៍។[10] តែបើយើងប្រៀបធៀបទៅនឹង ច្បាប់ភូមិបាល ឆ្នាំ២០០១ សញ្ញាណនៃអចលនវត្ថុត្រូវបានបែងចែកជាបីប្រភេទ គឺ អចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និង អចលនវត្ថុតាមការកំណត់របស់ច្បាប់ ប៉ុន្តែច្បាប់នេះបាននិរាករណ៍ទៅហើយ។

អចលនវត្ថុពីកំណើត គឺជាវត្ថុទាំងឡាយណាដែលកើតពីដីធម្មជាតិ ដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬ ទឹកហូរ និងសំណង់ ឬ ការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬ ផ្លាស់ប្តូរកន្លែងបាន។

អចលនវត្ថុពីភ័ព្វវាសនា មានវត្ថុដែលជាប់នឹងដី ឬ បញ្ចូលជាមួយសំណង់ទាំងឡាយណាដែលមិនអាចបំបែកចេញបានដោយមិនធ្វើឲ្យមានការខូចខាត ឬ មិនដូរសភាពដើមដូចជា ដើមឈើ ឧបករណ៍តែងលំអជាដើម។

អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និង ចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។ ឧទាហរណ៍ ដូចជា នាវាជាដើម។

ហើយការបញ្ចាំអចលនវត្ថុនេះ ក៏មានចែងនៅក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៨៣៥ ដល់ ៨៣៩ ប៉ុន្តែមិនបានបកស្រាយឲ្យបានលំអិតនោះទេ គឺផ្តោតសំខាន់តែទៅលើ អចលនវត្ថុជាដីធ្លី និងវត្ថុជាប់នៅលើដី ដូចជា ផ្ទះ អាគារ សំណង ដីធ្លី តែប៉ុណ្ណោះ។

**១.១.៣.៣. ការបញ្ចាំសិទ្ធិ**

ការបញ្ចាំសិទ្ធិ គឺជាសញ្ញាណថ្មីមួយដែលប្រទេសយើងមិនធ្លាប់មានពីមុនមក ប៉ុន្តែមកដល់សម័យឥឡូវនេះការបញ្ចាំសិទ្ធិត្រូវបានយកមកចងក្រងនៅក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ដែលមានបញ្ញត្តិក្នុងមាត្រា ៨៤០ ដល់មាត្រា ៨៥២។

[10] មាត្រា ៨៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

យើងបានដឹងហើយថា ការបញ្ចាំត្រូវបានធ្វើក្រោមរូបភាព ៣ យ៉ាងគឺ ការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិ។ ហើយនៅក្នុងក្រមរដ្ឋប្បវេណីក៏បានចែងថា ការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន[11] ដូចនេះមានន័យថាសិទ្ធិលើបំណុលក៏អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំបានដែរ។ លក្ខណៈខុសគ្នានៃការបញ្ចាំសិទ្ធិ និងការបញ្ចាំចលនវត្ថុ និងអចលនវត្ថុគឺត្រង់ថា ការបញ្ចាំចលនវត្ថុ ឬ អចលនវត្ថុកូនបំណុលត្រូវប្រគល់វត្ថុទៅឲ្យម្ចាស់បំណុលដើម្បីកាន់កាប់ ប៉ុន្តែការបញ្ចាំសិទ្ធិ គឺមិនអាចយកវត្ថុមកដាក់បញ្ចាំបានទេ ព្រោះវាជាវត្ថុអរូបិយ ដែលមិនអាចកាន់ ឬ ប៉ះពាល់បាន និងមិនអាចមើលឃើញបានឡើយ នៅត្រង់នេះបើយើងគិតទៅបើការបញ្ចាំសិទ្ធិមិនមានអ្វីយកទៅសំអាងតើវាអាធ្វើទៅបានទេ? ហើយដើម្បីឲ្យកិច្ចសន្យាបញ្ចាំសិទ្ធិមានអានុភាពតើត្រូវមានអ្វីជាសំអាង?

ការបញ្ចាំសិទ្ធិ គឺត្រូវតែមានវត្ថុសំអាង គ្រាន់តែវត្ថុនោះជាលិខិតមួយច្បាប់ដែលបញ្ជាក់ពីសិទ្ធិលើទ្រព្យសម្បត្តិ ឬ វត្ថុនោះជាសិទ្ធិដែលអាចក្លាយជាសិទ្ធិលើការបញ្ចាំបានមានដូចជា សិទ្ធិអ្នកនិពន្ធ កម្មសិទ្ធិបញ្ញា និងសិទ្ធិលើបំណុល។ សិទ្ធិលើបំណុលនេះគឺជាសិទ្ធិដែលសំដៅលើកូនបំណុល យកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះកូនបំណុលទី៣ ទៅដាក់បញ្ចាំឲ្យម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួន ដើម្បីធានានូវការសងបំណុល។ ឧទាហរណ៍ លោក **ក** បានខ្ចីប្រាក់ពីលោក **ខ** ចំនួន ៥០០០ ដុល្លារ។ ដោយលោក **ខ** ត្រូវការប្រាក់ជាបន្ទាន់ ហើយកិច្ចសន្យានោះមិនទាន់ដល់ពេលកំណត់ត្រូវសង ដូចនេះលោ **ខ** បានសម្រេចចិត្តទៅខ្ចីប្រាក់ពីលោក **គ** ចំនួន ៣០០០ ដុល្លារ តែដោយគាត់ពុំមានអ្វីយកទៅដាក់ធានាលើបំណុល គាត់អាចយកសិទ្ធិលើបំណុលរបស់គាត់ជាមួយ និងលោក **ក** ដែលមានចំនួន ៥០០០ ដុល្លារនោះទៅដាក់បញ្ចាំបាន។ ប៉ុន្តែនៅប្រទេសកម្ពុជាយើងពុំទាន់ឃើញមានប្រើប្រាស់ នូវសញ្ញាណនេះនៅឡើយទេ ពីព្រោះដោយសារការយល់ដឹងរបស់ប្រជាជននូវមានកម្រិត ណាមួយវាជាច្បាប់ដែលទើបបង្កើតឡើង ដែលជាហេតុនាំឲ្យប្រជាជនមិនយកមកប្រើប្រាស់។

## ១.២. ប្រតិបត្តិការបញ្ចាំនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី

ប្រតិបត្តិការបញ្ចាំនៅធនាគារ អេស៊ីលីដា ភីអិលស៊ី មាននីតិវិធី និងលក្ខខណ្ឌទទួលបានឥណទានមួយចំនួន ដែលមានការបកស្រាយដូចខាងក្រោម។

[11] មាត្រា ៨៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.២.១. ការព្រមព្រៀងលើសេវា

ការព្រមព្រៀងលើសេវាមានន័យថា ភាគីដែលស្នើសុំខ្ចីប្រាក់ ដែលហៅថាកូនបំណុល បានព្រមព្រៀងទទួលយកនូវសំណើ ឬ លក្ខខណ្ឌនៃភាគីម្ខាងទៀតដែលហៅថា ម្ចាស់បំណុល បើនិយាយឲ្យស្រួលស្តាប់ គឺជាអ្នកដែលទៅខ្ចីប្រាក់នៅធានាគារ អេស៊ីលីដា បានយល់ព្រមទៅ និងសំណើដែលធនាគារបានដាក់មក ដូចជា ធានាគារតម្រូវឲ្យមាន វត្ថុដាក់ធានា មានទីលំនៅពិតប្រាកដ មានប្រវត្តិល្អ មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាដើម និងជាពិសេសគឺជាជនដែលមានសមត្ថភាពបង្ហាញ ឆន្ទៈ យើងអាចនិយាយបានថាជានីតិជន ដែលមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាស់នៃសកម្មភាពរបស់ខ្លួន។[12] ដោយសារនៅធនាគារ អេស៊ីលីដា មានប្រភេទ ឥណទានជាច្រើនដែលមានលក្ខណៈស្រដៀងគ្នា ដែលធ្វើឲ្យប្រជានជនមិនសូវយល់ហើយពិបាកក្នុងការទទួលបាននូវឥណទានផងដែល។ ដូចនេះបានជាខ្ញុំសុំលើកយកនូវចំនុចសំខាន់ៗមួយចំនួនដើម្បីយកបកធ្វើការបកស្រាយ។

#### ១.២.១.១. ប្រភេទសេវាឥណទាន នៅធនាគារ អេស៊ីលីដា

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភេទសេវាឥណទានជាច្រើន ដែលស្របទៅតាមតម្រូវការទីផ្សារ និងតម្រូវការរបស់ប្រជាជន ហើយធនាគារផ្តល់ប្រាក់កម្ចី ជាប្រាក់រៀល ប្រាក់បាត និងដុល្លារអាមេរិក ទៅតាមតម្រូវការជាក់ស្តែងរបស់អតិថិជន។ ទំហំនៃប្រភេទឥណទានត្រូវកំណត់ដូចខាងក្រោម៖

#### ក. ឥណទានខ្នាតតូចបំផុត

ឥណទានខ្នាតតូចបំផុតជាប្រភេទឥណទានដែលមានប្រាក់កម្ចី មិនសូវច្រើនដូចប្រភេទឥណ-ទានផ្សេងៗទៀត ហើយធនាគារអេស៊ីលីដាបានដាក់លក្ខណៈពិសេសមួយចំនួនដូចជា៖

- អតិថិជនអាចខ្ចីជាឯកត្តជន(ទោល) ឬ ជាក្រុម
- អតិថិជនអាចសងប្រាក់មុនកាលកំណត់បាន ហើយធនាគារ អេស៊ីលីដា នឹងគិតការប្រាក់លើសមតុល្យដែលនៅសល់។

[12] មាត្រា ១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- សមាជិកឥណទានក្រុមម្នាក់ៗ អាចខ្ចីរហូតដល់៥,០០០,០០០៛ ឬ ៥០,០០០បាត។ សម្រាប់ឯកត្តជន អាចខ្ចីរហូតដល់៦,០០០,០០០៛ ឬ ៦០,០០០បាត ឬ ១,៥០០ដុល្លារ។

- ការសងប្រាក់ត្រូវអនុវត្តទៅតាមកាលវិភាគសងប្រាក់ដែលបានព្រមព្រៀង។

- ចំពោះឥណទានក្រុមសមាជិកត្រូវធានាគ្នាទៅវិញទៅមក។

- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះតែអតិថិជនដែលសងប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេលខ្ចី ឬ រក្សារយៈពេលខ្ចីនៅដដែល (អនុវត្តបានចំពោះឥណទានទោលតែប៉ុណ្ណោះ សម្រាប់ឥណទានក្រុមមិនត្រូវបានអនុញ្ញាតទេ)។

ទំហំឥណទាន ខ្នាតតូចបំផុតនៅធនាគារអេស៊ីលីដា ចែកចេញជា ៣ ប្រភេទមានជាប្រាក់រៀល ដែលមានទំហំប្រាក់កម្ចីរហូតដល់ ៦,០០០,០០០ រៀល ចណែកឯឥណទានជាប្រាក់បាតមានទំហំប្រាក់កម្ចីរហូតដល់ ៦០,០០០ បាត និងឥណទានជាប្រាក់ដុល្លារមានទំហំប្រាក់កម្ចីរហូតដល់ ១,៥០០ ដុល្លារអាមេរិក។

រយៈពេលខ្ចីប្រាក់នៅធនាគារអេស៊ីលីដា សំរាប់ឥណទានខ្នាតតូចបំផុតនេះ អតិបរមា ១៨ ខែ (រយៈពេលខ្ចីប្រាក់អាស្រ័យទៅលើទំហំឥណទាន)។ ហើយការសងប្រាក់ទៅឲ្យធនាគារវិញមានរយៈពេល ១សប្តាហ៍ ២សប្តាហ៍ ៤សប្តាហ៍ និង១ខែម្តង ទៅតាមទំហំឥណទាន ឬ តាមការជ្រើសរបស់កូនបំណុល។

**ខ. ឥណទានខ្នាតតូច**

ធនាគារអេស៊ីលីដា បានចែងលក្ខណៈពិសេសមួយចំនួនទាក់ទិននឹងឥណទានខ្នាតតូច ដែលមានខ្លឹមសារដូចជា៖

- ទទួលបានប្រាក់កម្ចីច្រើនជាង និងរយៈពេលវែងជាងឥណទានខ្នាតតូចបំផុត
- មានប័ណ្ណកម្មសិទ្ធិកាន់កាប់អចលនវត្ថុ(ប្លង់រឹង) សម្រាប់ប្រាក់កម្ចីលើសពី៤.០០០ដុល្លារឡើង។ ករណីពិសេសលិខិតកាន់កាប់ ឬ លិខិតផ្ទេរសិទ្ធិ ដីធ្លី ផ្ទះ(ប្លង់ទន់) ធនាគារអេស៊ីលីដា អាចផ្តល់ប្រាក់កម្ចីជូនដែរ។
- ខ្ចីបានជាឯកត្តជន(ទោល)

- អតិថិជនអាចសងប្រាក់មុនកាលកំណត់វិញបាន ហើយធនាគារ នឹងគិតការប្រាក់លើសមតុល្យឥណទានដែលនៅសល់ប៉ុណ្ណោះ។
- ការសងប្រាក់ត្រូវអនុវត្តឲ្យបានទៀងទាត់ទៅតាមកាលវិភាគសងប្រាក់ ដែលបានព្រមព្រៀង។
- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះតែអតិថិជនដែលសងប្រាក់ដើមលើសពីចំនួនកំណត់ ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេលខ្ចី ឬ រក្សារយៈពេលខ្ចីនៅដដែល។

ប្រភេទទំហំឥណទានខ្នាតតូចនេះធនាគារអេស៊ីលីដាបានកំណត់ប្រាក់កម្ចីជា ៣ ប្រភេទដូចគ្នា ប្រាក់រៀលមាន ប្រាក់កម្ចីធំជាង ៦.០០០.០០០៛ រហូតដល់ក្រោម ៤០.០០០.០០០៛ ឯប្រាក់បាតមានប្រាក់កម្ចីធំជាង ៦០.០០០បាត រហូតដល់ក្រោម ៤០០.០០០ បាត និងប្រាក់ដុល្លារមានប្រាក់កម្ចីធំជាង ១.៥០០ដុល្លារ រហូតដល់ក្រោម ១០.០០០ ដុល្លារ។

នៅក្នុងឥណទានខ្នាតតូចនេះរយៈពេលខ្ចីអតិបរិមា ២៤ខែ (រយៈពេលខ្ចីប្រាក់អាស្រ័យទៅលើទំហំឥណទាន)។ ការសង់ត្រឡប់មកធនាគារវិញ មានជំរើសច្រើនសំរាប់ជ្រើសរើសដូចជា មានរយៈពេល ២សប្តាហ៍ ៤សប្តាហ៍ និង ១ខែម្តង ទៅតាមលទ្ធភាពរបស់អតិថិជន។

**គ. ឥណទានខ្នាតមធ្យម**

ឥណទានខ្នាតមធ្យមជាប្រភេទឥណទានមួយដែល ធនាគារបានផ្តល់ប្រាក់កម្ចីដល់អតិថិជន ហើយវាមានលក្ខណៈពិសេសមួយចំនួនដល់អតិថិជន ក្នុងការស្នើរសុំប្រាក់កម្ចីដែលមានលក្ខខណ្ឌដូចជាៈ

- អតិថិជនទទួលបានប្រាក់កម្ចីច្រើនជាង និងរយៈពេលវែងជាងឥណទានខ្នាតតូច។
- អតិថិជនត្រូវមានប័ណ្ណកម្មសិទ្ធកាន់កាប់អចលនវត្ថុ (ប្លង់រឹង) ករណីពិសេសលិខិតកាន់កាប់ ឬ លិខិតផ្ទេរសិទ្ធដីធ្លី ផ្ទះ (ប្លង់ទន់) ធនាគារអេស៊ីលីដាអាចផ្តល់ប្រាក់កម្ចីជូនបានដែរ។
- ឥណទានដែលមានទំហំចាប់ពី ៣០០.០០០ដុល្លារឡើងទៅ តម្រូវឲ្យមានការបញ្ជាក់ពីមេធាវី។
- អតិថិជននឹងចំណាយសោហ៊ុយ១% នៃទំហំឥណទានដែលបានអនុម័ត

- អតិថិជនដាក់ធានាជាសន្និធិទំនិញបាន ប៉ុន្តែទំហំឥណទានមិនត្រូវ លើសពី ៥០%នៃតម្លៃមធ្យមសមតុល្យសន្និធិទំនិញដែលបានដាក់ធានា។
- អតិថិជនដាក់ធានានៅទឹកប្រាក់ក្នុងគណនីមានកាលកំណត់បាន ប៉ុន្តែទំហំឥណទានត្រូវតិចជាង១០០%នៃទឹកប្រាក់ក្នុងគណនីមានកាលកំណត់ ហើយអត្រាការប្រាក់គឺគិតតាមអត្រាការប្រាក់បញ្ញើ បូក៣% ទៅ ៥%បន្ថែម។
- អាចផ្តល់ឥណទានបន្ថែមលើសមតុល្យឥណទានចាស់ ករណីមុខរបរមានការរីកចម្រើន ឬ ការផ្តល់ឥណទានលើកមុនមិនទាន់អស់លទ្ធភាព និងមានទ្រព្យសម្បត្តិធានាគ្រប់គ្រាន់។

- ចំពោះឥណទានដែលមានទំហំចាប់ពី ១០.០០០ ដុល្លារ ឬ សមមូល អតិថិជនអាចបង្វែរប្រាក់កម្ចី ឬ សងប្រាក់ផ្តាច់មុនកាលកំណត់បានដោយពុំមានប្រាក់ពិន័យលើការប្រាក់ដែលនៅសល់ឡើយ។

- អតិថិជនអាចសងប្រាក់មុនកាលកំណត់បាន ប៉ុន្តែសម្រាប់ឥណទាន ដែលមានទំហំចាប់ពី១០០.០០០ ដុល្លារឡើងទៅត្រូវបង់ ១% លើសមតុល្យឥណទានដែលនៅសល់។

- ការសងប្រាក់ត្រូវអនុវត្តឲ្យបានទៀងទាត់ទៅតាមកាលវិភាគសងប្រាក់ ដែលបានព្រមព្រៀង។

ឥណទានខ្នាតមធ្យមរបស់ធនាគារអេស៊ីលីដាចែកចេញជា ៣ ប្រភេទដែលមានទំហំឥណ-ទានជាប្រាក់រៀល ចាប់ពី ៤០.០០០.០០រៀល ចំណែកប្រាក់បាតចាប់ពី ៤០០.០០០បាត និងប្រាក់ដុល្លារចាប់ពី ១០.០០០ដុល្លារ អាមេរិក រហូតដល់ ៥% នៃមូលនិធិសរុប របស់ធនាគារ អេស៊ី-លីដា។ ការសង់ត្រឡប់ទៅធនាគារវិញមានរយ:ពេល ១ខែម្តង។

### ឃ. ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ជាប្រភេទឥណទានដែលធនាគារអេស៊ីលីដាបានផ្តល់ប្រាក់កម្ចីដល់អតិថិជនសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ហើយធនាគារក៏មានលក្ខណ:ពិសេសមួយចំនួនដល់អតិថិជនផងដែរ លក្ខណ:ទាំងនោះមានដូចជា៖

- ឥណទាននេះសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ មិនមែនសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មឡើយ។

- ករណីអតិថិជន កំពុងប្រើប្រាស់សេវាបើកប្រាក់បៀវត្សជាមួយធនាគារអេស៊ីលីដាអតិថិជន អាចខ្ចីបានរហូតដល់៥០០ដុល្លារ ដោយមិនតម្រូវឲ្យមានទ្រព្យដាក់ធានា ប៉ុន្តែត្រូវមាន លិខិតបញ្ជាក់ពីអ្នកគ្រប់គ្រងផ្ទាល់ដែលអាចធានាបាននូវហានិភ័យឥណទាន។

- សោហ៊ុយចំណាយ ១% នៃទំហំឥណទានចាប់ពី ១០,០០០ដុល្លារ អាមេរិក ឬ សមមូល។

- អតិថិជនអាចសងប្រាក់មុនកាលកំណត់វិញបាន ហើយធនាគារអេស៊ីលីដា និងជូនការ ប្រាក់៧៥%វិញ លើការប្រាក់ដែលនៅសល់ទាំងអស់។

- អាចផ្តល់ឥណទានបន្ថែមលើសមតុល្យឥណទានចាស់ ករណីមុខរបរមានការរីកចម្រើន ឬ ការផ្តល់ឥណទានលើកមុន មិនទាន់អស់លទ្ធភាព និងមានទ្រព្យសម្បត្តិធានាគ្រប់គ្រាន់។

- ការសងប្រាក់ត្រូវអនុវត្តឲ្យបានទៀងទាត់ ទៅតាមកាលវិភាគសងប្រាក់ដែលបានព្រម ព្រៀង។

- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះអតិថិជនដែលសង ប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេល ខ្ចី ឬ រក្សារយៈពេលខ្ចីនៅដដែល។

ធនាគារអេស៊ីលីដា មានប្រភេទឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនហើយប្រភេទឥណ ទាន នេះមានទំហំឥណទាន អតិបរិមា ៣០.០០០ ដុល្លារអាមេរិក ឬ សមមូលជាប្រាក់រៀល និង ប្រាក់ បាត។ ហើយរយៈពេលខ្ចី អតិបរិមា ៣៦ខែ តែអាចមានរយៈពេលតិច ឬ ច្រើនអាស្រ័យទៅ លើទំហំឥណទាន។

**ខ. ឥណទានវិបារូបរ៍**

នៅក្នុងធនាគារអេស៊ីលីដាមានប្រភេទឥណទានវិបារូបរ៍ ហើយឥណទានប្រភេទនេះធនាគារ អេស៊ីលីដាបានកំណត់នូវលក្ខណៈពិសេសមួយចំនួនដូចជា៖

- អតិថិជនអាចដាក់ធានាជាសន្និធិទំនិញបាន ប៉ុន្តែទំហំឥណទានមិនត្រូវលើសពី ៥0% នៃ តម្លៃមធ្យមសមតុល្យសន្និធិទំនិញដែលបាន ដាក់ធានា។

- អតិថិជនអាចដាក់ធានា នូវទឹកប្រាក់ក្នុងគណនីមានកាលកំណត់បាន ប៉ុន្តែទំហំឥណទានត្រូវតិចជាង១00% នៃទឹកប្រាក់ក្នុងគណនីនោះ ហើយអត្រាការប្រាក់ គឺគិតតាមអត្រាការប្រាក់បញ្ញើ បូក៣% ទៅ ៥% បន្ថែម។
- អតិថិជនគួរមានប្រតិបត្តិការសាច់ប្រាក់ចូលគណនីរបស់អតិថិជន យ៉ាងតិច ៥0% នៃសាច់ប្រាក់ដែលបានដកប្រើប្រាស់ជារៀងរាល់ខែ។
- ករណីអតិថិជន មានប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីផ្នែកឥណទានវិបារូបរ៍តិចតួចមិនអាចសងការប្រាក់បាននៅរៀងរាល់៣ខែជាប់ៗគ្នា ឥណទាននោះ និងត្រូវផ្ទេរទៅជាផលិតផលឥណទានផ្សេង។
- សម្រាប់ឥណទានដែលមានទំហំចាប់ពី ៣០០,០០០ ដុល្លារអាមេរិកឡើងតម្រូវឲ្យមានការបញ្ជាក់ពីមេធាវីដោយធនាគារ អេស៊ីលីដា ជាអ្នកចាត់ចែងកិច្ចការនេះ ហើយរាល់ការចំណាយជាបន្ទុករបស់អតិថិជន។
- ធនាគារ អេស៊ីលីដា អាចផ្តល់ឥណទានបន្ថែមលើសមតុល្យឥណទានវិបារូបរ៍ចាស់ ដោយអនុលោមតាមនីតិវិធី និងសិទ្ធក្នុងការអនុមតិឥណទាន។
- ការបន្ត ឬ រំកិលឥណទានវិបារូបរ៍ ត្រូវធ្វើឡើងយ៉ាងតិច មួយខែមុនកាលបរិច្ឆេទបញ្ចប់ឥណទានវិបារូបរ៍ នោះដោយឆ្លងកាត់ការវិភាគហើយត្រូវបង់រាល់សោហ៊ុយឥណទានវិបារូបឡើងវិញ។
- ធនាគារអេស៊ីលីដានឹងជូនដំណឹងមុន១៥ថ្ងៃ មុននឹងដល់ថ្ងៃកាលអវសាននៃកិច្ចសន្យា។
- អតិថិជនសោហ៊ុយរៀបចំឯកសារ ១00ដុល្លារអាមេរិក ឬ សមមូលហើយត្រូវបង់នៅពេលចុះកិច្ចសន្យា។
- អតិថិជនបង់សោហ៊ុយបម្រុងសាច់ប្រាក់ ១ % លើទំហំឥណទានវិបារូបរ៍

ដោយឥណទានវិបារូបរ៍នេះជាប្រភេទឥណទាន ដែលធនាគារអេស៊ីលីដាបានផ្តល់ប្រាក់កម្ចីជាប្រាក់រៀល មានទំហំឥណទានចាប់ពី ២០.០០០.០០០រៀល ឯប្រាក់បាតមានទំហំចាប់ពី ២០០.០០០ បាត និងប្រាក់ដុល្លារមានទំហំចាប់ពី ៥.០០០ដុល្លារអាមេរិក រហូតដល់ ៥% នៃ

មូលនិធិសម្បត្តិសុទ្ធរបស់ធនាគារអេស៊ីលីដា។ ចំណែកឯរយៈពេលខ្ចីធនាគារអេស៊ីលីដា បានកំណត់អតិបរិមា ១២ខែ។

### ច. ឥណទានវិបារូបរ័សម្រាប់អតិថិជនបញ្ញើ-សន្សំ

ឥណទានវិបារូបរ័សម្រាប់អតិថិជនបញ្ញើសន្សំនេះ ជាប្រភេទឥណទានដែលមានលក្ខណៈស្រដៀងទៅ នឹងឥណទានវិបារូបរ័ដែរ ហើយឥណទានប្រភេទនេះក៏មានលក្ខណៈពិសេសមួយចំនួនផងដែរដូចជា៖

- ការដកសាច់ប្រាក់មួយលើកៗ ត្រូវទូទាត់សងត្រឡប់មកវិញមិនឲ្យហួស រយៈពេល១ខែ ក្នុងករណីលើសពីរយៈពេលនេះ ការដកប្រាក់បន្តត្រូវបានបញ្ឈប់រហូតដល់ការសងប្រាក់គោរពទៅតាមការព្រមព្រៀងឡើងវិញ។
- ថ្លៃរៀបចំឯកសារ ១០ដុល្លារអាមេរិក ឬ សមមូលប្រាក់រៀល និងប្រាក់បាត។
- មិនគិតថ្លៃសេវាសោហ៊ុយចំណាយបម្រុងសាច់ប្រាក់ទុក។
- មិនតម្រូវឲ្យអតិថិជនមានទ្រព្យធានា ឬ មានទឹកប្រាក់ក្នុងគណនីសម្រាប់ដាក់ធានាទេ។
- ចំពោះ អ្នករួមគណនីត្រូវដឹងឮ និងព្រមពៀងចុះកិច្ចសន្យា ខ្ចីឥណទានវិបារូបរ័សម្រាប់ប្រាក់បញ្ញើសន្សំនេះដែរ ហើយព្រមព្រៀងសងជំនួសនៅពេលអ្នកទទួលឥណទានវិបារូបរ័ខកខានមិនបានសងតាមកិច្ចសន្យា។

ប្រភេទឥណទានវិបារូបរ័សម្រាប់ប្រាក់បញ្ញើសន្សំនេះ មានទំហំឥណទានចាប់ពី ៥០% នៃទំហំសាច់ប្រាក់ជាមធ្យមដែលអតិថិជនធ្លាប់ដាក់ចូលក្នុងគណនី រយៈពេល៣ខែចុងក្រោយតែមិនត្រូវលើសពី ៥០០ដុល្លារ ឬ សមមូលជាប្រាក់រៀល និងប្រាក់បាត។ ចំណែកឯ អតិថិជនដែលកំពុងប្រើប្រាស់សេវាបើកប្រាក់បៀវត្សជាមួយធនាគារអេស៊ីលីដា ទំហំឥណទាន ៥០% នៃប្រាក់បៀវត្សសុទ្ធខែមុន។ ហើយឥណទានប្រភេទនេះមានរយៈពេលខ្ចី អតិបរិមា ១២ខែ។

### ឆ. ឥណទានសម្រាប់ទុនបង្វិល

ឥណទានសម្រាប់ទុនបង្វិល ក៏មានលក្ខណៈពិសេសដូចនឹងប្រភេទឥណទាន ផ្សេងៗដែរ ហើយលក្ខណៈពិសេសទាំងនោះមានដូចខាងក្រោម៖

- អតិថិជនអាចដាក់ធានាជាសន្និធិទំនិញបាន ប៉ុន្តែទំហំឥណទានមិនអាចលើសពី ៥០% នៃតម្លៃមធ្យមសមតុល្យសន្និធិទំនិញដែលបានដាក់ធានា និងតម្រូវឲ្យមានលិខិតបញ្ជាក់ពីមេធាវី។
- អតិថិជនអាចដាក់ធានា នូវទឹកប្រាក់ក្នុងគណនីបាន ប៉ុន្តែទំហំឥណទានត្រូវតិចជាង ១០០% នៃទឹកប្រាក់ក្នុងគណនីមានកាលកំណត់ ហើយអត្រាការប្រាក់គឺគិតតាមអត្រាការប្រាក់បញ្ញើបូកបន្ថែម ៣% ទៅ ៥%។
- សោហ៊ុយបម្រុងសាច់ប្រាក់ ១% លើកម្រិតបន្ទាត់ឥណទាន។
- សោហ៊ុយរៀបចំឯកសារ ១០០ ដុល្លារអាមេរិក ឬ សមមូលហើយត្រូវបង់នៅពេលចុះកិច្ចសន្យា។
- សម្រាប់ឥណទានដែលមានទំហំចាប់ពី ៣០០.០០០ ដុល្លារអាមេរិក តម្រូវឲ្យមានការបញ្ជាក់ពីមេធាវីដោយធនាគារ អេស៊ីលីដា ជាអ្នកចាត់ចែងកិច្ចការនេះ ហើយរាល់ចំណាយជាបន្ទុករបស់អតិថិជន។
- ការសុំដកប្រាក់តម្រូវឲ្យសរសេរជាលាយលក្ខណ៍អក្សរយ៉ាងហោចណាស់ឲ្យបានមុនពីរថ្ងៃនៃថ្ងៃធ្វើការ។
- ដកប្រាក់អប្បបរមា១.០០០ដុល្លារ ឬ សមមូលនឹងត្រូវធ្វើឡើងតាមពហុគុណនៃ ១.០០០ ដុល្លារ ឬ សមមូល។
- ការសងត្រឡប់មុនកាលកំណត់ នៃលិខិតសន្យាដែលពាក់ព័ន្ធត្រូវបានអនុញ្ញាតប៉ុន្តែអតិថិជន ត្រូវជូនដំណឹងឲ្យបានមុនយ៉ាងតិចបីថ្ងៃ។

ដោយសារប្រភេទឥណទានសម្រាប់ទុនបង្វិលនេះធនាគារអេស៊ីលីដាបានកំណត់ទំហំឥណទានចាប់ពី ១០.០០០ ដុល្លារអាមេរិក ឬ សមមូល រហូតដល់៥% នៃមូលនិធិសម្បត្តិសុទ្ធរបស់ធនាគារអេស៊ីលីដា។ ហើយមានរយៈពេលខ្លី អតិបរិមា ១២ខែ។

### ៤. កម្រិតបន្ទាត់ឥណទាន

ប្រភេទនៃឥណទាននៅធនាគារអេស៊ីលីដាមានច្រើន ហើយប្រភេទឥណទានខ្លះប្រជាជនមួយចំនួនមិនបានដឹង និងយល់ឡើយហើយក៏មានចម្ងល់ថាអ្វីទៅជាកម្រិតបន្ទាត់ឥណទាន?

កម្រិតបន្ទាត់ឥណទាន គឺជាចំនួនទឹកប្រាក់អតិបរមាដែលធនាគារបានកំណត់ ឬ សន្យាថានឹងឲ្យអតិថិជនខ្ចី (ឯកត្តជន ឬ ក្រុមហ៊ុន ) ដោយផ្អែកលើលទ្ធភាព អាចទទួលឥណទានបានរបស់អតិថិជន។ ម្យ៉ាងទៀត កម្រិតបន្ទាត់ឥណទាន មិនទាន់ក្លាយជាឥណទានទេ នៅពេលអតិថិជន មិនទាន់ដកប្រាក់យកទៅប្រើប្រាស់។ ដោយសារធនាគារអេស៊ីលីដា ចង់ឲ្យអតិថិជនគោរព និងធ្វើតាមការសន្យាទើបបង្កើតលក្ខណៈពិសេសមួយចំនួនដើម្បីការពារទុកជាមុន និងដើម្បីឲ្យអតិថិជនបានដឹងពីលក្ខខណ្ឌដើម្បីទទួលបានប្រាក់កម្ចីផងដែរ ហើយលក្ខណៈពិសេសទាំងនោះមានដូចជា៖

- ការផ្តល់ហិរញ្ញប្បទាន យោងទៅលើលំហូរសាច់ប្រាក់ និងទ្រព្យធានា។
- រយៈពេលខ្ចីអតិបរិមារហូតដល់ ២៤ខែ សម្រាប់កម្រិតបន្ទាត់ឥណទានដែលប្រើប្រាស់សម្រាប់គាំទ្រសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដោយត្រូវសិក្សា និងវាយតម្លៃឥណទានរៀងរាល់មួយឆ្នាំម្តង ហើយអតិថិជនត្រូវបង់រាល់សោហ៊ុយចំណាយឡើងវិញ។
- អតិថិជនបង់សោហ៊ុយបម្រុងសាច់ប្រាក់ ១% លើកម្រិតបន្ទាត់ឥណទាន។
- ករណីកម្រិតបន្ទាត់ឥណទានដែលប្រើប្រាស់គាំទ្រផលិតផលហិរញ្ញប្បទាន ពាណិជ្ជកម្ម (លិខិតឥណទាន ឬលិខិតធានា) ដែលមានរយៈពេលវែង ជាងនៃរយៈពេលកម្រិតបន្ទាត់ឥណទាន ការសងត្រឡប់ត្រូវបានអនុញ្ញាតឲ្យពន្យារ ឲ្យស៊ីគ្នាទៅនឹងរយៈពេលផលិតផលហិរញ្ញប្បទានពាណិជ្ជកម្ម។
- អតិថិជនបង់សោហ៊ុយរៀបចំឯកសារ ១០០ ដុល្លារអាមេរិក ឬ សមមូលហើយត្រូវបង់នៅពេលចុះកិច្ចសន្យា។ ករណីទំហំឥណទានចាប់ពី១០.០០០ដុល្លារអាមេរិក ឬសមមូលដោយផ្តល់អត្រាការប្រាក់ចន្លោះពី០,៨៣%ទៅ១% ត្រូវបង់សោហ៊ុយរៀបចំឯកសារ ២០០ដុល្លារអាមេរិក ឬសមមូល។
- អតិថិជនអាចដាក់ធានាជាសន្និធិទំនិញបាន ប៉ុន្តែទំហំឥណទានមិនលើសពី ៥0% នៃតម្លៃមធ្យមសមតុល្យសន្និធិទំនិញដែលបានដាក់ធានា និងតម្រូវឲ្យមានលិខិតបញ្ជាក់ពីមេធាវី។
- អតិថិជនអាចដាក់ធានានូវទឹកប្រាក់ក្នុងគណនីមានកាលកំណត់បាន ប៉ុន្តែទំហំឥណទានត្រូវតិចជាង១00%នៃទឹកប្រាក់ក្នុងគណនីមានកាលកំណត់ ហើយអត្រាការប្រាក់គឺគិតតាមអត្រាការប្រាក់បញ្ញើបូកបន្ថែម ៣%ទៅ៥%។

- សម្រាប់ឥណទានដែលមានទំហំចាប់ពី៣០០.០០០ដុល្លារអាមេរិក តម្រូវឲ្យមានការបញ្ជាក់ពីមេធាវី ដោយធនាគារ អេស៊ីលីដា ជាអ្នកចាត់ចែងកិច្ចការនេះ ហើយរាល់ការចំណាយជាបន្ទុករបស់អតិថិជន។
- ករណីអតិថិជន មិនបានប្រើប្រាស់ទៅតាមគោលបំណងដែលបានស្នើសុំពីដំបូងឥណទាននេះត្រូវបានអនុញ្ញាតឲ្យបង្វែរទៅជាឥណទានវិបារូបរ៍ ឬ ឥណទានទុនបង្វិលទៅតាមតម្រូវការរបស់អតិថិជនដោយរក្សាលក្ខខណ្ឌដដែល និងត្រូវមានការអនុញ្ញាតពីធនាគារ អេស៊ីលីដា។
- ការសងប្រាក់ត្រូវអនុវត្តតាមកិច្ចសន្យាដែលបានព្រមព្រៀង។
- ធនាគារ អេស៊ីលីដា រក្សាឆន្ទានុសិទ្ធរបស់ខ្លួនក្នុងការបញ្ឈប់ឲ្យប្រើប្រាស់នូវកម្រិតបន្ទាត់ឥណទានមួយផ្នែក ឬ ទាំងមូល ឬ តម្រូវឲ្យតិថិជនសងមកធនាគារវិញនូវសាច់ប្រាក់ទាំងអស់ដែលបានដកប្រើប្រាស់ នៅពេលលក្ខខណ្ឌណាមួយនៃកម្រិតបន្ទាត់ឥណទានមិនត្រូវបានបំពេញ ឬ នៅពេលដែលស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនមានទំនោរអន់ថយ។

នៅក្នុងប្រភេទនៃកម្រិតបន្ទាត់ឥណទាននេះធនាគារ អេស៊ីលីដា បានកំណត់ពីទំហំឥណទានដោយអ្នកខ្ចីអាច ខ្ចីប្រាក់កម្ចីតិចជាង ឬស្មើ ៨០% នៃតម្លៃទ្រព្យសម្បត្តិសុទ្ធផ្ទាល់របស់អតិថិជន និងមានរយៈពេល អតិបរិមា ១២ខែ។

**ឈ. ឥណទានគេហដ្ឋាន**

ឥណទានគេហដ្ឋានគឺជាឥណទានមួយដែលពេញនិយមផងដែរនៅក្នុងសង្គមបច្ចុប្បន្ន ហើយធនាគារអេស៊ីលីដាបានបង្កើតឥណទានប្រភេទនេះ ដើម្បីសម្រួលដល់ប្រជាជនសាមញ្ញដែលមិនមានប្រាក់គ្រប់គ្រាន់ទិញផ្ទះ ដើម្បីទទួលបានឥណទានប្រភេទនេះអតិថិជនត្រូវគោរពលក្ខណៈពិសេសដូចខាងក្រោម៖

- ករណីអតិថិជនមានតម្រូវការលក់គេហដ្ឋានដែលបានខ្ចីធនាគារទិញ ឬ សង់នោះ ការទូទាត់ទិញ-លក់ត្រូវធ្វើឡើងតាមរយៈគណនីឯករាជ្យ (Trust Account) នៅធនាគារ អេស៊ីលីដា ហើយភាគីទិញ-លក់ត្រូវបង់ប្រាក់គ្រប់ចំនួនចូលគណនី ទើបធនាគារ អេស៊ីលីដា ប្រគល់ប័ណ្ណកម្មសិទ្ធិ និងចេញលិខិតរួចបំណុលជូន។

- អតិថិជនសោហ៊ុយចំណាយរៀបចំឯកសារ ២៥០ ដុល្លារ។
- អតិថិជនបង់សោហ៊ុយចំណាយឥណទាន ១% លើទំហំឥណទាន។
- ទំហំឥណទានមិនលើសពី ៧០% នៃតម្លៃសរុបរបស់គេហដ្ឋានដែលត្រូវទិញ ឬសង់លើដីកម្មសិទ្ធដែលមានស្រាប់នោះឡើយ។
- មិនតម្រូវឲ្យទិញប័ណ្ណធានារ៉ាប់រងអគ្គិភ័យលើគេហដ្ឋានោះទេ ប្រសិនបើតម្លៃដីធំជាងទំហំប្រាក់កម្ចី មានន័យថាតម្លៃដីបូកតម្លៃផ្ទះធំជាងពីរដងនៃប្រាក់កម្ចី ឬ ទំហំប្រាក់កម្ចីត្រឹម ៣០.០០០ ដុល្លារអាមេរិក។
- អតិថិជនអាចបង់ប្រាក់ផ្តាច់មុនកាលកំណត់បាន។
- អតិថិជនត្រូវធ្វើវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុ ហើយត្រូវប្រគល់ជូនមកធនាគារ ដើម្បីដាក់ជាទ្រព្យធានាចំពោះកម្ចីទិញផ្ទះ។
- អតិថិជនអាចពន្យាពេលប្រគល់វិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន ករណីរដ្ឋាភិបាលចុះធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុតាមតំបន់ ដែលចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ប៉ុន្តែអតិថិជនត្រូវស្នើសុំមកធនាគារ អេស៊ីលីដា។
- ការសងប្រាក់ត្រូវអនុវត្តតាមកិច្ចសន្យា និងកាលវិភាគសងប្រាក់ដែលបានព្រមព្រៀង។
- អាចផ្តល់ប្រាក់កម្ចីចំពោះអ្នកដែលមានអាយុមិនលើសពី៦០ឆ្នាំ រាប់ចាប់ពីពេលទទួលប្រាក់កម្ចីរហូតដល់កាលាវសាននៃរយៈពេលខ្ចី។

ប្រភេទឥណទានគេហដ្ឋាន ធនាគារ អេស៊ីលីដា បានផ្តល់ឥណទានដល់អតិថិជន អតិបរមា ២០០.០០០ដុល្លារ ហើយមានរយៈពេលខ្ចី អតិបរិមា ១០ឆ្នាំ។

### ញ. ឥណទានរថយន្ត

ឥណទានរថយន្តក៏ជាប្រភេទឥណទានមួយដែលបានផ្តល់ប្រយោជន៍ជាច្រើនដល់អតិថិជន គឺដើម្បីសម្រួលដល់ការរស់នៅ និងមធ្យោបាយធ្វើដំណើរ ដើម្បីទទួលបាននូវឥណទានប្រភេទនេះ ធនាគារអេស៊ីលីដា តម្រូវឲ្យគោរពលក្ខណៈពិសេសដូចខាងក្រោម៖

- ឥណទានរថយន្តត្រូវបានផ្តល់ជូនជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ
- ឥណទានរថយន្តត្រូវបានផ្តល់ដើម្បីទិញរថយន្តថ្មី ឬទិញរថយន្តដែលប្រើហើយស្របច្បាប់ ដែលផលិតក្នុងអំឡុង ១០ឆ្នាំមុននៃឆ្នាំបច្ចុប្បន្ន។
- តម្រូវឲ្យទិញប័ណ្ណធានារ៉ាប់រងលើការបាត់បង់ និងខូចខាតរថយន្តសម្រាប់រយៈពេលនៃប្រាក់កម្ចី និងធ្វើស្លាកលេខប័ណ្ណសម្គាល់យានយន្ត ចុះបញ្ជីទប់ស្កាត់នៅមន្ទីរសាធារណៈ-ការ និងដឹកជញ្ជូន។រាល់ការចំណាយជាបន្ទុករបស់អតិថិជន ហើយ ធនាគារអេស៊ីលីដា ចាត់ចែងការងារនេះ។
- ករណីដាក់រថយន្តជាទ្រព្យធានាត្រូវមានទុនផ្ទាល់ខ្លួនយ៉ាងតិច ៤០%នៃតម្លៃរថយន្ត។
- ករណីដាក់ដី ផ្ទះ ជាទ្រព្យធានាត្រូវមានទុនផ្ទាល់ខ្លួនយ៉ាងតិច ២០%នៃតម្លៃរថយន្ត និងតម្រូវឲ្យមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធចំពោះទំហំឥណ-ទានចាប់ពី ៨.០០០ ដុល្លារ។
- អតិថិជនអាចបង់ផ្តាច់មុនកាលកំណត់បាន ដោយមិនមានការពិន័យឡើយចំពោះឥណទានដែលមានទំហំចាប់ពី ១០.០០០ ដុល្លារ។
- ការសងប្រាក់ត្រូវអនុវត្តទៅតាមកិច្ចសន្យាដែលបានព្រមព្រៀង។
- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះតែអតិថិជនដែលសងប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែល។

ប្រភេទឥណទានរថយន្តនេះ ធនាគារអេស៊ីលីដា បានផ្តល់ឥណទានដល់អតិថិជន អតិបរិមារហូតដល់ ១០០.០០០ ដុល្លារ និងមានរយៈពេល អតិបរិមា ៥ឆ្នាំ អាស្រ័យលើប្រភេទរថយន្ត និងមិនលើសពីអាយុចូលនិវត្តន៍ (សម្រាប់កម្មករនិយោជិត) ឬ មិនលើសពីអាយុ៦០ឆ្នាំ (សម្រាប់អតិថិជនទូទៅ)។

ឥណទានប្រភេទនេះ អាចសងដោយផ្អែកលើប្រាក់បៀវត្ស : សំណងមិនលើសពី **៥0%** នៃប្រាក់បៀវត្សសុទ្ធប្រចាំខែ ចំពោះអ្នកដែលមានប្រាក់បៀវត្ស ច្រើនជាង៤០០ដុល្លារឡើងទៅ។

ប្រសិនបើប្រាក់បៀវត្ស រហូតដល់ ៨០០ដុល្លារ សំណងមិនលើស **៥0%** នៃប្រាក់បៀវត្សសុទ្ធប្រចាំខែ។ ហើយមានការសងមួយប្រភេទទៀត ចំពោះអតិថិជនដែលមានចំណូលមិនមែនប្រាក់បៀវត្សសំណងប្រចាំខែ មិនលើសពី ៦៧ % នៃ ប្រាក់ចំណូលសុទ្ធដែលនៅសល់ និងចំពោះអតិថិជនដែលមានប្រភពចំណូលទាំងពីរ ការសងប្រចាំខែ ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងពីរខាងលើ។

**ខ. ឥណទានកែលម្អលំនៅឋាន**

ឥណទានកែលម្អលំនៅឋានវាជាឥណទានមួយជួយដល់ប្រជាពលរដ្ឋ ដែលមិនមានប្រាក់គ្រប់គ្រាន់ក្នុងការជួសជួលផ្ទះរបស់ខ្លួនភ្លាមៗ ដូចនេះទើបធនាគារអេស៊ីលីដាបានបង្កើតនូវប្រភេទឥណទាននេះឡើង ហើយដើម្បីទទួលបាននូលឥណទាននេះអតិថិជនត្រូវគោរពតាមលក្ខណៈពិសេសមួយចំនួនដូចជា៖

- ឥណទាននេះអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់តែការកែលម្អលំនៅឋាន ជាកម្មសិទ្ធិផ្ទាល់ខ្លួនដែលមានស្រាប់តែប៉ុណ្ណោះ។
- ត្រូវមានអាយុមិនលើសពី ៦០ឆ្នាំ ចាប់ពីពេលទទួលប្រាក់កម្ចីរហូតដល់កាលាវសាននៃរយៈពេលខ្ចី។
- គេហដ្ឋានដែលត្រូវកែលម្អដោយប្រាក់កម្ចីជាទ្រព្យសម្រាប់ដាក់ធានា ឬមានដី ផ្ទះផ្សេងទៀតដែលអាចដាក់ធានាជំនួសបាន។
- គេហដ្ឋានដែលត្រូវកែលម្អមិនស្ថិតក្នុងតំបន់ហាមឃាត់ ឬ សំណង់អនាធិបតេយ្យទេ។
- ករណីគេហដ្ឋានកែលម្អដោយប្រាក់កម្ចីត្រូវបានលក់ អតិថិជនត្រូវទូទាត់សងទាំងប្រាក់ដើម និងការប្រាក់គ្រប់ចំនួនមកធនាគារមិនលើសរយៈពេល១ខែ បន្ទាប់ពីការជូនដំណឹងរបស់ធនាគារ អេស៊ីលីដា។

ឥណទានកែលម្អលំនៅឋានធនាគារអេស៊ីលីដា បានកំណត់ទំហំឥណទាន ដែលមានប្រាក់កម្ចីអតិបរិមា ១០០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀល និងមានរយៈពេលអតិបរិមា ៥ឆ្នាំ។

### ផ. ឥណទានម៉ូតូ

ឥណទានម៉ូតូជាឥណទានមួយប្រភេទសំរាប់អតិថិជន ដែលមិនមានប្រាក់ទាំងដុលសំរាប់ទិញម៉ូតូ ដើម្បីទទួលបាននូវឥណទានប្រភេទនេះអតិថិជនត្រូវគោរពតាមលក្ខណ:ពិសេសដូចជាៈ

- ឥណទានម៉ូតូត្រូវបានផ្តល់ជូនជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ
- ឥណទានម៉ូតូត្រូវបានផ្តល់ ដើម្បីទិញម៉ូតូថ្មីគ្រប់ប្រភេទ និងស្របច្បាប់
- អតិថិជនត្រូវទិញម៉ូតូពីអ្នកផ្គត់ផ្គង់ ដែលត្រូវបានជ្រើសរើសដោយធនាគារ អេស៊ីលីដា។
- តម្រូវឲ្យទិញប័ណ្ណធានារ៉ាប់រងលើការបាត់បង់ និងខូចខាតម៉ូតូសម្រាប់រយៈពេលនៃប្រាក់កម្ចី និងធ្វើស្លាកលេខ ប័ណ្ណសម្គាល់ម៉ូតូ ចុះបញ្ជីទប់ស្កាត់ នៅមន្ទីរសាធារណៈការ និងដឹកជញ្ជូន។ រាល់ការចំណាយជាបន្ទុករបស់អតិថិជនហើយធនាគារ អេស៊ីលីដា ចាត់ចែងការងារនេះ។
- ការទូទាត់ត្រូវធ្វើតែមួយលើកគត់ និងត្រូវធ្វើឡើងមិនលើសពីរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់។
- ធនាគារ អេស៊ីលីដា ផ្តល់ឥណទានអតិបរិមា ៨០%នៃតម្លៃម៉ូតូ និងតម្រូវឲ្យអតិថិជនដាក់ប្រាក់ចូលក្នុងគណនីរបស់ខ្លួន២០% នៃតម្លៃម៉ូតូ ដែលត្រូវទិញ(ករណីដាក់ម៉ូតូជាទ្រព្យធានា)។
- ករណីអតិថិជន ដាក់ដី ផ្ទះជាទ្រព្យធានាមិនតម្រូវឲ្យដាក់ប្រាក់ចូលក្នុងគណនីរបស់ខ្លួន ២០% នៃតម្លៃម៉ូតូដែលត្រូវទិញ និងមិនតម្រូវឲ្យអតិថិជនទិញធានារ៉ាប់រងឡើយ។
- ការសងប្រាក់ត្រូវអនុវត្តតាមកិច្ចសន្យាដែលបានព្រមព្រៀង។
- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះតែអតិថិជនដែលសងប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែល។

ឥណទានម៉ូតូគឺជាឥណទានមួយប្រភេទ ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការទិញម៉ូតូដោយមិនចាំបាច់មានប្រាក់ទាំងដុលសំរាប់ទិញឡើយ ហើយឥណទានប្រភេទនេះមានទំហំ អតិបរិមា ២៥០០ ដុល្លារ និង មានរយៈពេល អតិបរិមា ៣ឆ្នាំ និងមិនលើសពីអាយុចូលនិវត្តន៍ (៦០ឆ្នាំ) សម្រាប់កម្មករនិយោជិត និយោជក។

### ១.២.១.២. អត្រាការប្រាក់

អត្រាការប្រាក់ ត្រូវបានកំណត់ទៅតាមទំហំនៃឥណទាន និងប្រភេទផលិតផលឥណទាន។

#### ក. ឥណទានជាប្រាក់រៀល

- ឥណទានក្រុម

  អត្រាការប្រាក់ធំជាង ២,៨០% ទៅ ២,៧០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៥,០០០,០០០ រៀល។

- ឥណទានទោល

  អត្រាការប្រាក់ធំជាង ២,៨០% ទៅ ២,៧០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៦,០០០,០០០ រៀល។

  អត្រាការប្រាក់ធំជាង ២,២០% ទៅ ២,៨០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំធំជាង ៦,០០០,០០០ រៀល រហូតដល់ ២០,០០០,០០០ រៀល។

  អត្រាការប្រាក់ធំជាង ២,០០% ទៅ ២,៨០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំធំជាង ២០,០០០,០០០ រៀល រហូតដល់ក្រោម ៨០,០០០,០០០ រៀល។

#### ខ. ឥណទានជាប្រាក់បាត

- ឥណទានក្រុម

  អត្រាការប្រាក់ធំជាង ២,៨០% ទៅ ២,៧០% ក្នុងមួយខែ លើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំរហូតដល់ ៥០,០០០ បាត។

- ឥណទានទោល

អត្រាការប្រាក់ធំជាង ២,៤០% ទៅ ២,៧០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៦០,០០០ បាត។

អត្រាការប្រាក់ធំជាង ២,២០% ទៅ ២,៤០% ក្នុងមួយខែ លើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំធំជាង ៦០,០០០ បាត រហូតដល់ ២០០,០០០ បាត។

អត្រាការប្រាក់ធំជាង ២,០០% ទៅ ២,២០%ក្នុងមួយខែ លើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំធំជាង ២០០,០០០ បាត រហូតដល់ក្រោម ៤០០,០០០ បាត។

**គ. ឥណទានជាប្រាក់ដុល្លារអាមេរិក**

អត្រាការប្រាកធំជាង ២,៤០% ទៅ ២,៧០% ក្នុងមួយខែ លើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំរហូតដល់ ១,៥០០ ដុល្លារអាមេរិក។

អត្រាការប្រាក់ធំជាង ១,៧០% ទៅ ២,០០% ក្នុងមួយខែ លើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំធំជាង ១,៥០០ ដុល្លារអាមេរិក រហូតដល់ ៥,០០០ ដុល្លារអាមេរិក។

អត្រាការប្រាក់ធំជាង ១,៥០% ទៅ ១,៧០% ក្នុងមួយខែ លើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំធំជាង ៥,០០០ ដុល្លារអាមេរិក រហូតដល់ក្រោម ១០,០០០ ដុល្លារអាមេរិក។

**១.២.២. លក្ខខណ្ឌដើម្បីទទួលបានឥណទាន**

ដោយសារនៅធនាគារ អេស៊ីលីដា មានឥណទានច្រើនប្រភេទ ដូចនេះទើបខ្ញុំបាទសូមលើឡើងតែ ប្រភេទឥណទានមួយចំនួន ដូចជា ឥណទានគេហដ្ឋាន ឥណទានរថយន្ត និងម៉ូតូ ដើម្បីធ្វើការបកស្រាយ។

**១.២.២.១. ឥណទានគេហដ្ឋាន**

**ក. និយមន័យ**

ឥណទានគេហដ្ឋានជាប្រភេទផលិតផលឥណទាន ដែលធនាគារអេស៊ីលីដាបង្កើតសម្រាប់ផ្តល់ជូនសាធារណៈជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទិញ ឬ សាង់សង់គេហដ្ឋានលើដីកម្មសិទ្ធិដែលមានស្រាប់។ ធនាគារមិនអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគោលបំណងផ្សេងពីនេះឡើយ។

**ខ.ប្រភេទរូបិយប័ណ្ណ**

ឥណទានគេហដ្ឋានត្រូវបានផ្តល់ជូនអតិថិជនជាប្រាក់ដុល្លារអាមេរិក។

**គ.កំណត់ទំហំឥណទាន**

+ ទំហំឥណទានអតិបរិមា២០០,០០០ដុល្លារតែមិនត្រូវលើសពី ៦០% នៃតម្លៃសរុបគេហដ្ឋានដែលត្រូវទិញ ឬ សាងសង់ឡើយ។
+ អ្នកខ្ចីត្រូវមានទឹកប្រាក់ផ្ទាល់ខ្លួនយ៉ាងតិច ៤០% នៃតម្លៃគេហដ្ឋានដែលត្រូវទិញ ឬ សាងសង់។

**ឃ.រយៈពេលឥណទាន**

- រយៈពេលខ្ចីអតិបរិមា១០ឆ្នាំ (ដប់ឆ្នាំ) និងបែងចែកតាមប្រភេទអតិថិជនៈ
  + កម្មករនិយោជិតកំពុងបំរើការងារក្នុងស្ថាប័នសាធារណៈ និងទីភ្នាក់ងារជាតិ–អន្តរជាតិត្រូវមានអាយុចាប់ពីពេលទទួលប្រាក់កម្ចី រហូតដល់កាលាវសាននៃរយៈពេលខ្ចីប្រាក់មិនត្រូវ លើសពីអាយុចូលនិវត្តន៍ឡើយ។
  + អតិថិជនផ្សេងទៀត ត្រូវមានកាយសម្បទារឹងមាំ និងមានអាយុចាប់ពីពេលទទួលប្រាក់កម្ចីរហូតដល់កាលាវសាននៃរយៈពេលខ្ចីប្រាក់ មិនត្រូវលើសពីអាយុ៦០ឆ្នាំឡើយ។
- **ឥណទានគេហដ្ឋានដែលមានឯកសារកម្មសិទ្ធិជាកម្មសិទ្ធិជាប្លង់ទន់**
  + អត្រាការប្រាក់១៣% ក្នុងមួយឆ្នាំ (១៣% per annum) លើសសមតុល្យឥណទានចំពោះឥណទានដែលទ្រព្យធានាមានឯកសារកម្មសិទ្ធិប្លង់ទន់ជាគេហដ្ឋានដែល ទិញ/សាងសង់ដោយប្រាក់កម្ចីឥណទានគេហដ្ឋាន។

+ ប្រសិនបើអ្នកខ្ចីបាធ្វើប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) រួចរាល់ និងបានអត់លេខាចារឹកចុះបន្ទុកដាក់ធានាពីរដ្ឋបាលសុរិយោដីថ្នាក់ រាជធានី/ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ ក្រុង/ស្រុក/ខណ្ឌ ប្រគល់ជូនមកធនាគារអត្រាការប្រាក់ត្រូវបានកាត់បន្ថយមកត្រឹម ១១% ក្នុងមួយឆ្នាំលើសសមតុល្យឥណទានដែលនៅសល់គិតចាប់ពីថ្ងៃបានទទួលប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) រហូតដល់ចប់ កិច្ចសន្យាខ្ចីប្រាក់។

- **ឥណទានគេហដ្ឋានដែលមានកម្មសិទ្ធ (ប្លង់រឹង)**
  + អត្រាការប្រាក់១១% ក្នុងមួយឆ្នាំ (១១%per annum) លើសមតុល្យឥណទានចំពោះឥណទានដែលទ្រព្យធានាជាគេហដ្ឋានដែល ទិញ/សាងសង់ដោយប្រាក់កម្ចីឥណទានគេហដ្ឋាន ដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ឬទ្រព្យធានាជាដី/គេហដ្ឋាន ផ្សេងទៀតមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ជាកម្មសិទ្ធិរបស់អ្នកខ្ចីហើយបានរត់ការធ្វើលេខាចារឹកចុះបន្ទុកដាក់ធានាពីរដ្ឋបាល សុរិយោដីថ្នាក់ រាជធានី/ខេត្ត ឬរដ្ឋបាល សុរិយោដីថ្នាក់ក្រុង/ស្រុក/ខណ្ឌ។
- **ឥណទានគេហដ្ឋានដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) មិនទាន់កាត់ឈ្មោះ**
  + អត្រាការប្រាក់១២% ក្នុងមួយឆ្នាំ (១២% per annum) លើសសមតុល្យឥណទានសម្រាប់ឥណទានគេហដ្ឋានមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ដែលទិញដោយមិនទាន់បានកាត់ឈ្មោះផ្ទេរប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ពីរដ្ឋបាលសុរិយោដីថ្នាក់រាជធានី/ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង/ស្រុក/ខណ្ឌជាទ្រព្យដាក់ធានា។
  + ប្រសិនបើអ្នកខ្ចីបានកាត់ឈ្មោះផ្ទេរប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) រួចរាល់ និងបានរត់ការធ្វើលេខាចារឹកចុះបន្ទុកដាក់ធានាពីរដ្ឋបាលសុរិយោដីថ្នាក់ រាជធានី/ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ ក្រុង/ស្រុក/ខណ្ឌប្រគល់ជូនមកធនាគារអត្រាការប្រាក់ត្រូវបានកាត់ បន្ថយមកត្រឹម១១% ក្នុងមួយឆ្នាំលើសមតុល្យឥណទានដែល នៅសល់គិតចាប់ពីថ្ងៃ បានទទួលប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) រហូតដល់ចប់កិច្ចសន្យាខ្ចីប្រាក់។
- ការប្រាក់ត្រូវសងប្រចាំខែពេញរយៈពេលឥណទាន។

### ច.ការបើកប្រាក់កម្ចី

ការបើកកម្ចីត្រូវបានធ្វើឡើងតាមរយៈការផ្ទេរចេញពីគណនីរបស់ធនាគារចូលទៅគណនីរបស់អតិថិជននូវទឹកប្រាក់កម្ចីទាំងអស់តែមួយលើក ឬ តាមដំណាក់កាល (មិនលើសពី៣លើក) បន្ទាប់ពីបានព្រមព្រៀង និងចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់:

- **ទិញគេហដ្ឋានមានផ្ទះស្រាប់:**ការបើកប្រាក់កម្ចីត្រូវបានធ្វើឡើងតាមរយៈការ ផ្ទេរទឹកប្រាក់កម្ចីទាំងអស់តែមួយលើក ឬ តាមដំណាក់កាលដោយផ្អែកលើកិច្ចសន្យា ទិញ–លក់គេហដ្ឋាន។ ការបើកប្រាក់កម្ចីតាមដំណាក់កាលអ្នកខ្ចីត្រូវបង់ការប្រាក់ និងប្រាក់ដើមរៀងរាល់ខែតាមតារាងកាលវិភាគសងប្រាក់ហើយដំណាក់កាលផ្ទេរ ប្រាក់កម្ចីនៅលើកចុងក្រោយគឺនៅពេលគេហដ្ឋានដែលទិញបានផ្ទេរកម្មសិទ្ធិរួចរាល់ ជាស្ថាពរ។
- **គេហដ្ឋានកំពុងសាងសង់:**ការបើកប្រាក់កម្ចីត្រូវបានធ្វើឡើងតាមរយៈការផ្ទេរ ទឹកប្រាក់កម្ចីទាំងអស់តែមួយលើក ឬ តាមដំណាក់កាលដោយផ្អែកលើកិច្ចសន្យា ទិញ–លក់/សាងសង់ និងការវិវត្តន៍របស់សំណង់។ ការបើកប្រាក់កម្ចីតាមដំណាក់កាល អ្នកខ្ចីត្រូវបង់ការប្រាក់ និងប្រាក់ដើមរៀលរាល់ខែតាមតារាងកាលវិភាគសងប្រាក់ហើយដំណាក់កាលផ្ទេរទឹកប្រាក់កម្ចីនៅលើកចុងក្រោយគឺនៅពេលដែលគេហដ្ឋាន បាននឹងកំពុងដំណើរការសាងសង់លើសពី៧០ភាគរយ។

* ការបើកប្រាក់កម្ចីត្រូវធ្វើឡើងមិនលើសពីរយៈពេលមួយខែបន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់។

### ១.២.២.១. ឥណទានរថយន្ត និង ម៉ូតូ

#### ក. និយមន័យ

ឥណទានរថយន្ត និងម៉ូតូ គឺជាប្រភេទឥណទានដែលធនាគា អេស៊ីលីដាបង្កើតឡើងដើម្បីសម្រួលដលប្រជាជនទូទៅដែលមិនមានប្រាក់ទាំងដុលដើម្បីទិញរថយន្ត ឬម៉ូតូ។

**ភាពងាយស្រួល និង អត្ថប្រយោជន៍ដែលអតិថិជនទទួលបាន៖**

- រថយន្តតាមបំណងប្រាថ្នាដែលអាចសម្រួលដល់ការរស់នៅប្រចាំថ្ងៃ។
- ផ្ទេរចំណាយដុលនៃថ្លៃទិញរថយន្ត ទៅជាចំណាយប្រចាំខែ តាមរយៈការសងរំលោះមកធនាគារ អេស៊ីលីដា។
- អាចប្រើប្រាស់សេវាផ្សេងៗទៀតរបស់ធនាគារ អេស៊ីលីដា។
- បង្កើនសុខមាលភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារ។

- គ្រួសារមានសុភមង្គល និងទាន់សម័យ។

**ដើម្បីទទួលបានឥណទានរថយន្ត អតិថិជនគ្រាន់តែ ៖**

- ជានីតិជន
- ត្រូវមានប័ណ្ណបើកបរ
- មានច្បាប់ថតចម្លង សៀវភៅគ្រួសារ ឬ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។
- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុរយៈពេលមួយឆ្នាំចុងក្រោយ។
- សៀវភៅគណនី ឬ ថតចម្លងរបាយការណ៍គណនីរយៈពេលបីខែចុងក្រោយ (ប្រសិនបើមាន)
- ច្បាប់ថតចម្លងប័ណ្ណប៉ាតង់
- ច្បាប់ថតចម្លងវិក្ក័យបត្រទឹក និងភ្លើង បីខែ ចុងក្រោយ។
- កិច្ចសន្យាជួលទ្រព្យសម្បត្តិ(បើមាន)
- ធានាផ្តល់ព័ត៌មាន និងឯកសារត្រឹមត្រូវ គ្រប់គ្រាន់ នៅពេលធនាគារត្រូវការ។

**ខ. លក្ខណៈពិសេស**

- ឥណទានរថយន្តត្រូវបានផ្តល់ជូនជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ
- ឥណទានរថយន្តត្រូវបានផ្តល់ដើម្បីទិញរថយន្តថ្មី ឬទិញរថយន្តដែលប្រើហើយ ស្របច្បាប់ ដែលផលិតក្នុងអំឡុង ១០ឆ្នាំមុននៃឆ្នាំបច្ចុប្បន្ន។
- តម្រូវឲ្យទិញប័ណ្ណធានារ៉ាប់រងលើការបាត់បង់ និងខូចខាតរថយន្តសម្រាប់រយៈពេលនៃប្រាក់កម្ចី និងធ្វើស្លាកលេខ ប័ណ្ណសម្គាល់យានយន្ត ចុះបញ្ជីទប់ស្កាត់នៅមន្ទីរសាធារណៈការ និងដឹកជញ្ជូន។ រាល់ការចំណាយជាបន្ទុករបស់អតិថិជន ហើយ ធនាគារអេស៊ីលីដាចាត់ចែងការងារនេះ។

- ករណីដាក់រថយន្តជាទ្រព្យធានាត្រូវមានទុនផ្ទាល់ខ្លួនយ៉ាងតិច ៤០%នៃតម្លៃរថយន្ត។
- ករណីដាក់ដី ផ្ទះ ជាទ្រព្យធានាត្រូវមានទុនផ្ទាល់ខ្លួនយ៉ាងតិច ២០%នៃតម្លៃរថយន្ត និងតម្រូវឲ្យមានវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធចំពោះទំហំឥណទានចាប់ពី ៨.០០០ ដុល្លារ។
- អតិថិជនអាចបង់ផ្តាច់មុនកាលកំណត់បាន ដោយមិនមានការពិន័យឡើយចំពោះឥណទានដែលមានទំហំចាប់ពី ១០.០០០ ដុល្លារ។
- ការសងប្រាក់ត្រូវអនុវត្តទៅតាមកិច្ចសន្យាដែលបានព្រមព្រៀង។
- ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ត្រូវបានអនុញ្ញាតចំពោះតែអតិថិជនដែលសងប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែល។

**គ. ទំហំឥណទាន**

ប្រាក់កម្ចីអតិបរិមារហូតដល់ ១០០.០០០ ដុល្លារសំរាប់រថយន្ត និងប្រាក់កម្ចីអតិបរិមា ២៥០០ ដុល្លារសម្រាប់ម៉ូតូ។

រយៈពេល អតិបរិមា ៨ឆ្នាំ អាស្រ័យលើប្រភេទរថយន្ត និងមិនលើសពីអាយុចូលនិវត្តន៍ (សម្រាប់កម្មករនិយោជិត) ឬ មិនលើសពីអាយុ៦០ឆ្នាំ (សម្រាប់អតិថិជនទូទៅ)។ សម្រាប់ម៉ូតូអតិបរិមា ៣ឆ្នាំ និងមិនលើសពីអាយុចូលនិវត្តន៍ (៦០ឆ្នាំ)សម្រាប់កម្មករនិយោជិត និយោជក។

**របៀបសងប្រាក់**

- សងរំលស់ប្រាក់ដើមថេរ បូកជាមួយការប្រាក់ជារៀងរាល់ខែ
- សងរំលស់ប្រាក់ដើម បូកជាមួយការប្រាក់ថេរជារៀងរាល់ខែ

**ឃ. គំរិតនៃប្រាក់សំណង**

- ការសងដោយផ្អែកលើប្រាក់បៀវត្ស : សំណងមិនលើសពី **៥០%** នៃ ប្រាក់បៀវត្សសុទ្ធប្រចាំខែ ចំពោះអ្នកដែលមានប្រាក់បៀវត្ស ច្រើនជាង៤០០ដុល្លារឡើងទៅ។ ប្រសិនបើ

ប្រាក់បៀវត្ស រហូតដល់ ៥០០ដុល្លារ សំណងមិនលើស **៥0%** នៃប្រាក់បៀវត្សសុទ្ធប្រចាំខែ។

- ចំពោះអតិថិជនដែលមានចំណូលមិនមែនប្រាក់បៀវត្ស : សំណងប្រចាំខែ មិនលើសពី ៦៧ % នៃ ប្រាក់ចំណូលសុទ្ធដែលនៅសល់។
- ចំពោះអតិថិជនដែលមានប្រភពចំណូលទាំងពីរ ការសងប្រចាំខែ ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងពីរខាងលើ។

### ១.២.៣. ការសងត្រឡប់មកវិញនៃឥណទាន

នៅក្នុងការសងត្រឡប់មកវិញនៃឥណទាននេះ មានចំនុចពីរដូចជា របៀបសងប្រាក់ (១.២.៣.១) និងការសងត្រឡប់មកវិញ(១.២.៣.២) ដើម្បីឲ្យបានច្បាស់សូមលើខ្លឹមសារខាងក្រោម។

#### ១.២.៣.១. របៀបសងប្រាក់

ការសងត្រឡប់មកវិញនៃឥណទានគ្រប់ប្រភេទត្រូវ អនុវត្តទៅតាមតារាងកាលវិភាគសងប្រាក់ដែលបានចែងក្នុងកិច្ចសន្យា ហើយការសងប្រាក់នេះ ត្រូវអនុវត្តតាមចន្លោះកាលបរិច្ឆេទ ដូចជាសងរំលស់ទាំងប្រាក់ដើម និងប្រាក់ការ ឬ សងការប្រាក់ និងសងប្រាក់ដើមជាភាគរយ ហើយប្រាក់ដើមនៅសល់ត្រូវសងនៅចុងបញ្ចាប់នៃវគ្គខ្ចីប្រាក់ ឬ សងការប្រាក់ ហើយប្រាក់ដើមសងតាមការព្រមព្រៀង និងមានរបៀបសងមួយប្រភេទទៀតគឺ សងការប្រាក់ និងសងប្រាក់ដើមនៅចុងបញ្ចប់នៃវគ្គខ្ចីប្រាក់ តែចំនុចនេះអនុវត្តសម្រាប់តែឥណទានទោល ត្រូវអនុលោមតាមគោលការណ៍ណែនាំស្តីពី ឥណទានដែលសងតែការប្រាក់រៀងរាល់ខែ និងប្រាក់ដើមនៅចុងបញ្ចប់នៃវគ្គខ្ចីប្រាក់។

#### ១.២.៣.២. ការសងត្រឡប់មកវិញ

ភ្នាក់ងារឥណទានត្រូវធ្វើការវិនិយោគ និងវាយតម្លៃលទ្ធភាពសងរបស់អតិថិជន ដើម្បីធ្វើឲ្យប្រាកដ៏ថា ឥណទានត្រូវបានសងត្រឡប់មកវិញទាំងដើមទាំងការប្រាក់បានទាន់ពេលវេលា។ ហើយការវាយតម្លៃប៉ាន់ស្មានលទ្ធភាពសងបំណុល ដោយផ្អែកសំខាន់បំផុតលើចំណូលបច្ចុប្បន្នរបស់អ្នកខ្ចីជាមូលដ្ឋាន គឺមិនផ្អែកលើចំណូលដែលកើតមាន ឬ ប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលនឹងទទួលបាននៅពេលអនាគតទេ។ ប្រសិនបើចំណូលសំខាន់ៗពីមុខរបរមិនគ្រប់គ្រាន់សម្រាប់សងបំណុលទេ នោះអាចវិភាគលើចំណូលផ្សេងៗ តែត្រូវធ្វើការសិក្សាឲ្យបានល្អិតល្អន់ ធ្វើយ៉ាង

ណាបង្ហាញឲ្យឃើញថា អ្នកខ្ចីពិតជាមានលទ្ធភាពអាចសងបំណុលទាំងស្រុង។ ការសងត្រឡប់មកវិញនៃឥណទាន អនុវត្តទៅតាមតារាងកាលវិភាគសងប្រាក់ឲ្យបានត្រឹមត្រូវ តាមកិច្ចសន្យាកំណត់ ហើយការសងប្រាក់ គឺត្រូវអនុវត្តតាមចន្លោះកាលបរិច្ឆេទថេរ។ ប្រសិនបើអតិថិជនអាចសងបំណុលដាច់មុនការកំណត់ ការប្រាក់ត្រូវបានកាត់បន្ថយ ការប្រាក់ដែលត្រូវកាត់បន្ថយត្រូវបានគណនាសមាមាត្រទៅនឹងចំនួនថ្ងៃដែលសងដាច់មុនការកំណត់នោះ ប៉ុន្តែអតិថិជនត្រូវបង់ ២៥%(ម្ភៃប្រាំភាគរយ) លើចំនួនការប្រាក់ដែលនៅសល់។

## ១.២.៤. ការខកខានសង និងការពិន័យ

ការខកខានសង និងការពិន័យ គឺជាការដាក់បន្ទុកទៅលើកូនបំណុលដែលមានការយឺតយ៉ាវក្នុងការសងប្រាក់ត្រឡប់មកធនាគារ ដោយមានការពិន័យជាប្រាក់ជាដើម។

### ១.២.៤.១. ការខកខានសង

ឥណទានមួយត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យា កាលណាដល់ពេលវេលាសងហើយ អ្នកខ្ចីមិនបានសងទាន់ពេលវេលាកំណត់ ដូចមានចែងក្នុងកិច្ចសន្យា និងតារាងកាលវិភាគសងប្រាក់។ រយៈពេលខកខានសងប្រាក់ គឺជាចំនួនថ្ងៃដែលខកខានមិនបានសងតាមកិច្ចសន្យា រាប់ចាប់ពីថ្ងៃយឺតដំបូង ហើយរយៈពេលនេះ និងត្រូវបានកាត់បន្ថយ ក្នុងករណីទំហំទឹកប្រាក់បានសងសមាមាត្រទៅនឹទំហំទឹកប្រាក់នៃចន្លោះរយៈពេលយឺតយ៉ាវសងនោះ។ ចំណែកឯទឹកប្រាក់ខកខានសង គឺជាទឹកប្រាក់ដែលមិនបានសង ឬ សងមិនគ្រប់ចំនួនចាប់ពីថ្ងៃដំបូង។ ទឹកប្រាក់ដែលសងក្រោយត្រូវយកទៅបំពេញឲ្យទឹកប្រាក់មិនបានសង ឬ សងមិនគ្រប់ចំនួនពេលដំបូង រួចហើយកាត់សងបំពេញទៅទឹកប្រាក់មិនបានសង ឬ សងមិនគ្រប់ចំនួននៅពេលបន្តបន្ទាប់។

#### ក. ការខកខានសងកម្រិតស្រាល

ការខកខានសងកម្រិតស្រាល គឺជាការខកខានសងប្រាក់ ដែលទឹកប្រាក់មិនបានសង ឬ ទឹកប្រាក់សងមិនគ្រប់ចំនួន ហួសកាលកំណត់នៃកិច្ចសន្យារយៈពេលតិចជាង ៣០ថ្ងៃ។

#### ខ. ការខកខានសងធ្ងន់ធ្ងរ

ការខកខានសងធ្ងន់ធ្ងរ គឺជាការខកខានសងប្រាក់ ឬ ទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលចាប់ពី ៣០ថ្ងៃ។

**១.២.៤.២. ការពិន័យ**

ការពិន័យ កើតមានចំពោះអតិថិជនណា ដែលមិនបានគោរពតាមកិច្ចសន្យាឲ្យបានត្រឹមត្រូវ ដូចជាមានការយឺតយាវក្នុងការសងប្រាក់ទៅធនាគារវិញ ដែលជាហេតុនាំឲ្យមានការពិន័យ ដើម្បីកុំឲ្យកើតមាននូវករណីនេះម្តងទៀត ខាងក្រោមនេះយើងក៏បានពន្យល់ពីការពិន័យមួយចំនួនដែលទាក់ទងទៅនឹងបែបបទនៃធនាគារ អេស៊ីលីដាផងដែរ។

**ក. ពិន័យ**

ការខកខានសងបំណុលចាប់ពីរយៈពេល ០៤ ថ្ងៃឡើងទៅត្រូវបានគិតពិន័យ ហើយអត្រាពិន័យត្រូវបានគិតស្មើនឹង **២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ**។ ហើយទឹកប្រាក់ពិន័យត្រូវបានគណនាតាមអត្រាពិន័យ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រទៅនឹងចំនួនថ្ងៃដែលខកខានសងនោះ ចាប់គិតពីថ្ងៃទី ០៤ នៃការយឺតយ៉ាវសងឡើងទៅ។

**ខ. ការលុបចោលប្រាក់ពិន័យ**

នាយក-នាយិកា សាខាធនាគារអេស៊ីលីដា ភីអិលស៊ីមានសិទ្ធិសម្រេចលុបចោលប្រាក់ពិន័យ ក្នុងករណីមានហេតុផលសមរម្យដែលស្នើឡើងដោយភ្នាក់ងារឥណទាន និងមានសេចក្តីបញ្ជាក់ពីប្រធានការិយាល័យស្រុក-ខណ្ឌ-ក្រុង ឬ ប្រធាភ្នាក់ងារឥណទានសាខា។ ដើម្បីលុបប្រាក់ពិន័យ ត្រូវតែមានឯកសារយោងសម្រាប់ចុះបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ។

# ជំពូក២ ហ៊ីប៉ូតែក

ហ៊ីប៉ូតែក គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគដែលមានក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ហើយត្រូវបាននិរាករនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ជំនួសដោយក្រមរដ្ឋប្បវេណីឆ្នាំ២០១១។

## ២.១. សញ្ញាណទូទៅទាក់ទងហ៊ីប៉ូតែក

ហ៊ីប៉ូតែក ថាជាសិទ្ធិមួយដែលម្ចាស់បំណុល ហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់។[13]

ហ៊ីប៉ូតែក ជារបបគតិយុត្តិមួយនៃការធានាបំណុលដោយវត្ថុដែលត្រូវដាក់ជាប្រាតិភោគ។ សារៈប្រយោជន៍ដ៏ធំបំផុតមួយរបស់ហ៊ីប៉ូតែកគឺថា កូនបំណុលមិនចាំបាច់ផ្ទេរនូវការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកទៅឲ្យម្ចាស់បំណុលឡើយ ករណីនេះធ្វើឲ្យកូនបំណុលអាចបន្តការរស់នៅ ឬ ការធ្វើអាជីវកម្មនៅលើទ្រព្យរបស់ខ្លួននោះជាធម្មតាទោះបីជាទ្រព្យនោះកំពុងតែជាប់ហ៊ីប៉ូតែកក៏ដោយដែលចំណុចនេះហើយនាំឲ្យវាមានការខុសប្លែកពីការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដែលកូនបំណុលត្រូវតែផ្ទេរនូវការកាន់កាប់វត្ថុទៅឲ្យម្ចាស់បំណុល និងខុសប្លែកពីការធានាដោយវត្ថុ ដែលកូនបំណុលត្រូវតែផ្ទេរនូវប័ណ្ណកាន់កាប់វត្ថុនោះទៅឲ្យម្ចាស់បំណុល។ សារៈប្រយោជន៍មួយទៀតនៃហ៊ីប៉ូតែក គឺថាកូនបំណុលអាចបង្កើតហ៊ីប៉ូតែកច្រើននៅលើទ្រព្យនោះបានចំពោះម្ចាស់បំណុលច្រើនគ្នាទៀតផង ហើយដែលលំដាប់នៃការទទួលបានសំណងគឺអាស្រ័យទៅលើពេលវេលានៃការចុះបញ្ជីសុរិយោដីនៃបន្ទុកហ៊ីប៉ូតែកនោះ។

## ២.២. ការបង្កើតហ៊ីប៉ូតែក

ជាទូទៅ នៅក្នុងការបង្កើតកិច្ចសន្យាមួយត្រូវធ្វើឡើងឲ្យស្របនឹងស្វ័យភាពឆន្ទៈរបស់គូភាគី និងកម្មវត្ថុជាក់លាក់។ ការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ជាសិទ្ធិមួយដែលម្ចាស់បំណុលទទួលបាននូវសំណងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ចដោយកូនបំណុល និងជាប្រភេទនៃសិទ្ធិប្រាតិ-

[13] មាត្រា ៨៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ភោគប្រត្យក្ស[14] ដែលកូនបំណុល ឬ តតិយជនបានយកទ្រព្យសម្បត្តិមកដាក់ហ៊ីប៉ូតែក។ យើងអាចសម្គាល់បានថា ម្ចាស់បំណុលហ៊ីប៉ូតែកមានលក្ខណៈល្អប្រសើរជាងម្ចាស់បំណុលដែលមិនមានហ៊ីប៉ូតែក ពីព្រោះថាហ៊ីប៉ូតែកដើម្បីធានាបំណុលដែលជាប់ទាក់ទងទៅនឹងអចលនវត្ថុ។ ដូច្នេះដើម្បីឲ្យម្ចាស់បំណុលធានាបាននូវសិទ្ធិហ៊ីប៉ូតែកលើបំណុលរបស់ខ្លួន ត្រូវគោរពទៅតាមលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី(២.២.១) និងលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក (២.២.២)។

## ២.២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី

ដើម្បីកិច្ចសន្យាមួយមានអានុភាព និងសុពលភាពស្របតាមច្បាប់ គឺចាំបាច់ណាស់ត្រូវគោរពនូវលក្ខខណ្ឌសុពលភាពដូចចំណុច (២.២.១.១.ការព្រមព្រៀង) (២.២.១.២.សមត្ថភាពនៃគូភាគី) (២.២.១.៣.កម្មវត្ថុ)។

### ២.២.១.១. ការព្រមព្រៀង

ការសម្តែងឆន្ទៈរបស់គូភាគីក្នុងការបង្កើតកិច្ចសន្យាគឺជាធាតុផ្សំមួយដ៏សំខាន់។ ការបង្កើតហ៊ីប៉ូតែកក៏ដូចគ្នាដែរ គឺចាំបាច់ត្រូវមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល ឬជាមួយតតិយជនដែលបានយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ ដើម្បីធានាបំណុលហ៊ីប៉ូតែករបស់ខ្លួន។[15] ការបង្ហាញឆន្ទៈគឺត្រូវធ្វើឡើងដោយពិតប្រាកដ និងមិនមានវិការៈក្នុងការព្រមព្រៀង។ មានន័យថាកិច្ចសន្យាមួយត្រូវធ្វើឡើងដោយមានការព្រមព្រៀង មិនមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង និងគ្មានវិការៈក្នុងការសម្តែងឆន្ទៈ។

### ២.២.១.២. សមត្ថភាពនៃគូភាគី

ការបង្ហាញឆន្ទៈ គឺជាសេរីភាពរបស់បុគ្គលម្នាក់ៗ ប៉ុន្តែនៅក្នុងកិច្ចសន្យាការបង្ហាញឆន្ទៈចាំបាច់ត្រូវតែបង្ហាញដោយ សមត្ថជន ដែលមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន និងមានមានលក្ខណសម្បត្តិដែលអាចក្លាយជាម្ចាស់កម្មសិទ្ធិ

[14] សិទ្ធិប្រាតិភោគប្រត្យក្ស ជាសិទ្ធិប្រត្យក្សមួយប្រភេទ រួមមានសិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ច។ យោងតាមសន្ទានុក្រម រដ្ឋប្បវេណី ឆ្នាំ ២០០៧

[15] មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

និងកាតព្វកិច្ច គេហៅថាសមត្ថភាពទទួលសិទ្ធិ។ ម្យ៉ាងទៀត សមត្ថជន ដែលអាចធ្វើឲ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់ គឺជាសមត្ថភាពក្នុងការធ្វើសកម្មភាព។

ដែលបើកឱកាសឲ្យអនីតិជន អាចមានសិទ្ធិស្នើសុំគ្រប់គ្រងខ្លួន និងទ្រព្យសម្បត្តិរបស់ខ្លួនដោយខ្លួនឯង ឬ ស្វ័យភាពលើខ្លួនឯង។ បុគ្គលដែលទទួលបាននអត្តាធិនភាពពីតុលាការ ក៏អាចកំណត់ថាជាបុគ្គលមានសមត្ថភាពឧទាហរណ៍: បុគ្គលដែលអសមត្ថភាពក្នុងការយល់ដឹងអំពីសកម្មភាពនៃអំពើរបស់ខ្លួនដោយ កត្តាអាយុ ការសេពជាតិស្រវឹងហួសកំរិត ការប្រើប្រាស់គ្រឿងញៀន និង ជនវិបល្លាសស្មារតី ទុកថាគ្មានសមត្ថភាពខាងឆន្ទៈ។ តើបុគ្គលណាខ្លះ ជាជនដែលមានសមត្ថភាព ចុះកិច្ចសន្យាបាន?

សទ្ធានុក្រម នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សមត្ថជន សំដៅលើជនទាំងឡាយ ក្រៅពីជននៅក្រោមអាណាព្យាបាលទូទៅ និង ក្រៅពីជននៅក្រោមហិត្វូបត្ថម្ភ[16] និង អនីតិជន ដែលទទួលបានអត្តាធិនភាព។[17]

សមត្ថជនក៏សំដៅលើអនីតិជនដែលមានអត្តាធិនភាពផងដែរ អត្តាធិនភាព ត្រូវធ្វើការស្នើសុំពីតុលាការ។[18] អ្វីជាអត្តាធិនភាព? អត្តាធិនភាព ជាអំពើមួយធ្វើកិច្ច សន្យា។ ដូច្នេះការបង្កើតកិច្ចសន្យាហិរញ្ញវត្ថុហ៊ីប៉ូតែកក៏ទាមទារឲ្យភាគីនៃកិច្ចសន្យាត្រូវមានសមត្ថភាព ដើម្បីឲ្យកិច្ចសន្យាហ៊ីប៉ូតែក មានអានុភាពគតិយុត្ត។

នៅក្នុងគោលការណ៍ប្រតិបត្តិឥណទានរបស់ធនាគារអេស៊ីលីដាភី អិលស៊ីក៏បានកំណត់អំពីលក្ខណមនុស្សដែលអាចទទួលឥណទានបាន គឺរូបវន្តបុគ្គលជានីតិជនដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានប្រវត្តិ និងអត្តចរិតល្អ ដែលអាចជឿទុកចិត្តបាន
- ធានាផ្តល់ជូនព័ត៌មានជូនធនាគារ ត្រឹមត្រូវ ច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា

[16] ហិត្វូបត្ថម្ភ ជាការគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី។ យោងតាមសទ្ធានុក្រមទំព័រទី២៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[17] អត្តាធិនភាព ជាស្ថានភាពមួយដែលផ្តល់ឲ្យអនីតិជនរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។ យោងតាមសទ្ធានុក្រម ទំព័រទី២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[18] មាត្រា ២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការរបស់សាខាធនាគារទទួលខុសត្រូវ និងបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរក្នុងតំបន់ដែលខ្លួនរស់នៅ ដូចជាមានសៀវភៅស្នាក់នៅ ឬ សៀវភៅគ្រួសារ ឬ អត្តសញ្ញាណប័ណ្ណ
- មានមុខរបរ និងប្រាក់ចំណូលច្បាស់លាស់
- មានដី ផ្ទះ ឬ ទ្រព្យផ្សេងទៀតដែលអាចធានាលើប្រាក់កម្ចី
- យល់ច្បាស់រាល់ប្រការ និងលក្ខខណ្ឌនៃគោលការណ៍ និងនីតិវិធីឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី។

### ២.២.១.៣. កម្មវត្ថុ

គោលបំណងសំខាន់នៃកិច្ចសន្យា ជាចាំបាច់ត្រូវមានកម្មវត្ថុមួយដែលជាក់លាក់ និងស្របច្បាប់ ដែលកើតចេញពីឆន្ទៈរបស់គូភាគីជាម្ចាស់បំណុល និងកូនបំណុលដែលធ្វើ និងទទួលបានផលប្រយោជន៍។ ចំពោះកិច្ចសន្យាទាំងឡាយណាដែលមានកម្មវត្ថុដែលត្រូវបានហាមឃាត់ដោយច្បាប់ នោះកិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ។ នៅក្នុងមាត្រា ៨៤៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានកំណត់អំពីកម្មវត្ថុ ដែលអាចយកមកដាក់ជាហ៊ីប៉ូតែកបាន មានតែអចលនវត្ថុ សិទ្ធិជួលជាអចិន្ត្រៃយ៍ ផលុភោគ និង ទ្រព្យផ្សេងដែលមានចែងក្នុងច្បាប់។[19] វត្ថុនៅជាប់នឹងដីជាសមាសភាគនៃដី ដូចនេះនៅក្នុងក្រមរដ្ឋប្បវេណីនេះមិនចាត់ទុកដីជាអចលវត្ថុឯករាជ្យពីដីទេ[20] ក្នុងករណីនេះប្រសិនបើហ៊ីប៉ូតែកបានបង្កើតឡើងនៅលើដីមួយ ជាគោលការណ៍ហ៊ីប៉ូតែកនោះ ត្រូវមានអានុភាពលើអាគារដែលមាននៅលើដីហ៊ីប៉ូតែកនោះ។ ប៉ុន្តែក៏មានអញ្ញត្រកម្មផងដែរចំពោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬ ទ្រព្យដែលត្រូវបានរឹបអូសឃាត់ទុកពុំអាចដាក់ជាហ៊ីប៉ូតែកបានឡើយ។[21]

[19] មាត្រា ៨៤៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[20] មាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[21] យោងតាមនីតិប្រាតិភោគរបស់សាស្ត្រាចារ្យ ជាំង ស៊ីណាត ឆ្នាំ ២០០៦ - ២០០៧ (ទំព័រទី៨)

**២.២.១.៣.១. អចលនវត្ថុ**

អចលនវត្ថុ[22]ជាវត្ថុដែលជាប់នឹងកន្លែងតែមួយមិនអាចកម្រើកបាន ឬ មិនអាចផ្លាស់ប្តូរទីកន្លែងបានពីកំណើតក្តី(...)[23]។

**២.២.១.៣.២. សិទ្ធិជួលអចិន្ត្រៃយ៍**

ការជួលអចលនវត្ថុរយៈពេលវែងចាប់ពី១៥ឆ្នាំឡើងទៅ កំណត់ថាជាសិទ្ធិជួលអចិន្ត្រៃយ៍។ សិទ្ធិជួលរយៈពេលវែង ជាសិទ្ធិភណ្ឌិក[24] ហើយអាចផ្ទេរដោយមានថ្លៃ ឬ អាចធ្វើសន្តតិកម្មបាន។ សិទ្ធិជួលអចិន្ត្រៃយ៍ គឺមិនត្រូវធ្វើឲ្យលើសពីរយៈពេល៥០ឆ្នាំទេ មានន័យថាបើមានការជួលសិទ្ធិអចិន្ត្រៃយ៍ដែលមានរយៈពេលលើសពី៥០ឆ្នាំ ត្រូវបន្ថយមកត្រឹម៥០ឆ្នាំវិញ ហើយអាចធ្វើបន្តសិទ្ធិជួលអចិន្ត្រៃយ៍សារជាថ្មីបាន ប៉ុន្តែត្រឹមរយៈពេល៥០ឆ្នាំប៉ុណ្ណោះ។

សិទ្ធិជួលអចិន្ត្រៃយ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះបញ្ជីជាដាច់ខាតដើម្បីមានសិទ្ធិតតាំងជាមួយតតិយជន ប៉ុន្តែបើពុំបានធ្វើជាលាយលក្ខណ៍អក្សរទេ នោះនឹងក្លាយជាភតិសន្យាដែលពុំមានការកំណត់អំឡុងពេល និងត្រូវបញ្ឈប់ដោយភាគីម្ខាងទៀតនៅពេលណាក៏បាន។[25]

**២.២.១.៣.៣. ផលុបភោគ**

ផលុបភោគ សំដៅលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃក្នុងពេលកំណត់ណាមួយដែលមិនអាច លើសពីមួយជីវិតនៃផលុបភោគី។[26] ផលុប-ភោគ អាចត្រូវបង្កើតឡើងដោយច្បាប់ ឬ ដោយការព្រមព្រៀង និងមានការកំណត់ជាក់លាក់ ឬ មិនមានការកំណត់ជាក់លាក់ក៏បាន ហើយត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ និងមានការចុះបញ្ជីនៅមន្ទីសុរិយោដី។

[22] មាត្រា ១២០,១២១ និង មាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[23] មាត្រា ១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[24] សិទ្ធិភណ្ឌិក ជាសិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអះអាងចំពោះបុគ្គលដទៃទៀតបាន។ យោងតាមសទ្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[25] មាត្រា ៦១៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[26] មាត្រា ២៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.២.២.លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះដោយលិខិតយថាភូត[27] និងមិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ។ ដូច្នេះដើម្បីបំពេញតាមលក្ខខណ្ឌនៃការកំណត់របស់ច្បាប់ សម្រាប់ម្ចាស់សិទ្ធិលើហ៊ីប៉ូតែកពេញលេញអាចតតាំងនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនជាមួយតតិយជនបាន លុះត្រាហ៊ីប៉ូតែកត្រូវបានចុះបញ្ជី។[28]

ទំនាក់ទំនងគតិយុត្តិ មានពីរលក្ខខណ្ឌផ្សេងគ្នាគឺ លក្ខខណ្ឌសុពលភាពសម្រាប់គូភាគី និងលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក សម្រាប់តតិយជនដែលមិនមែនជាគូភាគី។ ហ៊ីប៉ូតែកដែលជាសិទ្ធិមួយដែលកើតឡើងតាមកិច្ចសន្យារបស់គូភាគីនោះ ក៏មានលក្ខខណ្ឌដោយឡែកសម្រាប់តតាំងជា មួយតតិយជនដែរ។ ដោយសារតែហ៊ីប៉ូតែកជាសិទ្ធិដែលមិនមែនមានឥទ្ធិពលចំពោះតែម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលចំពោះតតិយជនផ្សេងទៀតដូចជាជនដែលទិញដីដែលជាប់ហ៊ីប៉ូតែកនោះ និងម្ចាស់បំណុលផ្សេងទៀតដែលមិនមែនជាម្ចាស់បំណុលហ៊ីប៉ូតែក។ ហេតុនេះហើយ ការយល់ដឹងអំពីលក្ខខណ្ឌតម្រូវតាមច្បាប់សម្រាប់ឲ្យម្ចាស់ហ៊ីប៉ូតែកអាចតតាំងនូវសិទ្ធិហ៊ីប៉ូតែក របស់ខ្លួនជាមួយនឹងតតិយជនបានជាប្រការមួយដែលចាំបាច់។

ហ៊ីប៉ូតែកតម្រូវឲ្យមានការចុះបញ្ជីសុរិយោដី ដើម្បីជូនដំណឹងដល់សារធារណជនឲ្យបានដឹងចំពោះអចលនវត្ថុមួយចំនួនត្រូវបានដាក់ជាហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកនឹងទទួលបាននូវការសងសិទ្ធិលើបំណុលរបស់ខ្លួនពីអចលនវត្ថុហ៊ីប៉ូតែកនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងដ៏ទៃទៀត។ ហេតុនេះវាទាមទារឲ្យមានការប្រកាសជាសាធារណៈនូវសិទ្ធិនោះតាមរយៈការចុះបញ្ជីសុរិយោដីដើម្បីឲ្យតតិយជន ក្រៅពីគូភាគីនៃកិច្ចសន្យាអាចមើលឃើញ និងបានដឹងអំពីសិទ្ធិនោះ។ នៅពេលដែលមានការចុះបញ្ជីហ៊ីប៉ូតែកនោះហើយសូម្បីតែអ្នកដែលទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកដោយការចុះបញ្ជីនោះ ក៏មិនអាចបដិសេធនូវអានុភាពនៃហ៊ីប៉ូតែកនោះបានទេ។ និយាយម្យ៉ាងទៀត អ្នកទិញអាចធ្វើលទ្ធកម្មនូវដីដែលមានជាប់បន្ទុកហ៊ីប៉ូតែកតែប៉ុណ្ណោះ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែក អាចតតាំងនូវហ៊ីប៉ូតែករបស់ខ្លួន។

[27] លិខិតយថាភូតជា លិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀតគឺជា លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។
[28] មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២.៣. អានុភាពនៃហ៊ីប៉ូតែក

ក្រោយពីបានបង្កើតកិច្ចសន្យា និងគោរពលក្ខខណ្ឌសុពលភាព ព្រមទាំងលក្ខខណ្ឌតតាំង រួចហើយនោះ កិច្ចសន្យាបង្កើតឲ្យមានអានុភាព។ យើងនឹងធ្វើការសិក្សាទៅលើទំហំអានុភាព ហ៊ីប៉ូតែក(២.៣.១) ឧបាទេសកម្ម(២.៣.២) សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ(២.៣.៣) លំដាប់នៃហ៊ីប៉ូតែក(២.៣.៤) ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា(២.៣.៥)។

### ២.៣.១.ទំហំនៃអានុភាពហ៊ីប៉ូតែក

នៅពេលដែលហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ហ៊ីប៉ូតែកនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារដែលមាននៅលើដីដែលជាប់ហ៊ីប៉ូតែកនោះផងដែរ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬ ក្រោយពេលបង្កើតហ៊ីប៉ូតែកក៏ដោយ ហើយដែលភាគីមិនអាចកំណត់នូវលក្ខខណ្ឌផ្សេងពីនេះ នៅក្នុងកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួនបានឡើយ។[29]

ការកំណត់បែបនេះដោយហេតុថា មាត្រា ១២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងថា វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដីហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ហេតុនេះនាំឲ្យសិទ្ធិហ៊ីប៉ូតែកដែលមាននៅលើដីមួយកន្លែង នឹងមានអនុភាពទៅលើអ្វីដែលជាសមាសភាគនៃដីនោះផងដែរ។

សិទ្ធិហ៊ីប៉ូតែកនៅលើអចលនវត្ថុមួយកន្លែង មិនមានអនុភាពទៅលើផលដែលកើតចេញពីអចលនវត្ថុនោះទេ មិនថាជាផលស៊ីវិល ឬ ផលធម្មជាតិឡើយ។ ដោយសារតែហ៊ីប៉ូតែក ត្រូវបានបង្កើតជាថ្នូរទៅនឹងតម្លៃនៅលើអចលនវត្ថុមួយដើម្បីធានាកាតព្វកិច្ច ប៉ុន្តែអ្នកបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុមួយ គឺនៅតែមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផល លើអចលនវត្ថុនោះដដែល ដូចនេះផលជាកម្មសិទ្ធិរបស់អ្នកធានាដោយវត្ថុ។ មានន័យថា ទោះបីជាដី ឬ អាគារត្រូវបានដាក់ហ៊ីប៉ូតែកហើយក៏ដោយ ក៏ថ្លៃឈ្នួលដែលកើតចេញពីដី ឬ អាគារនោះនៅតែជារបស់អ្នកធានាដោយវត្ថុដដែល។ ប៉ុន្តែក្នុងករណីដែលអចលនវត្ថុ ដែលជាប់ហ៊ីប៉ូតែកនោះត្រូវបានលក់ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើនូវលទ្ធកម្ម កម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងត្រូវបាត់បង់កម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនេះដែរ។ សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលលើអចលនវត្ថុរបស់អ្នកបង្កើតហ៊ីប៉ូតែកនោះក៏ត្រូវរលត់ដែរ។

[29] មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.៣.២. ឧបាទេសកម្ម

ហ៊ីប៉ូតែក គឺជាសិទ្ធិដែលបានប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។[30] ដូច្នេះម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះសាច់ប្រាក់ ឬ វត្ថុផ្សេងដទៃទៀតដែលចេញមកអំពីមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ពីព្រោះថាហេតុទាំងនោះត្រូវបានចាត់ទុកជាការទទួលស្គាល់ ឬ បំផ្លែងនូវតម្លៃនៃអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ។ ប៉ុន្តែម្ចាស់សិទ្ធិហ៊ីប៉ូតែកពុំអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងទៀតត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើត។ ហេតុផលដែលមានការកំណត់យ៉ាងដូច្នេះដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតឡើង និងអាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះប៉ុន្តែនៅក្រោយពេលតម្លៃបានបំផ្លែង ឬ កើតចេញពីការលក់ ឬ បាត់បង់វត្ថុជាក់លាក់នោះត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើតហ៊ីប៉ូតែកនោះហើយ ចាប់តាំងពីពេលនោះមកវា មិនអាចបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតបានទេ។ ហេតុនេះហ៊ីប៉ូតែកមិនអាចអនុវត្តចំពោះទ្រព្យនោះបានទៀតទេ។ ដូច្នេះបើសិនជាម្ចាស់បំណុលចង់អនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនឲ្យបានមុនការប្រគល់ប្រាក់ ឬ វត្ថុដែលកើតចេញពីមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតចំពោះកម្មវត្ថុនោះទៅឲ្យកូនបំណុលហ៊ីប៉ូតែក។

### ២.៣.៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ច នោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើហ៊ីប៉ូតែកដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុលដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា (មាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។ បញ្ញត្តិនេះ ឆ្លើយតបទៅនឹងការធានារដោយទ្រព្យមាត្រា ៧៦៦ ការធានារបំណុលដោយបុគ្គលមាត្រា៩០០ និងមាត្រា៩១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

### ២.៣.៤. លំដាប់នៃហ៊ីប៉ូតែក

កិច្ចសន្យាហ៊ីប៉ូតែក បានផ្តល់ប្រយោជន៍ដល់កូនបំណុលក្នុងការខ្ចីប្រាក់ពីម្ចាស់បំណុលជាច្រើនរហូតដល់គ្រប់តម្លៃនៃអចលនវត្ថុ។ តើនៅពេលមានបញ្ហា ម្ចាស់បំណុលហ៊ីប៉ូតែកទាំងនោះត្រូវសងតាមលំដាប់យ៉ាងដូចម្តេច?

[30] មាត្រា ៨៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កូនបំណុល អាចបង្កើតសិទ្ធិហ៊ីប៉ូតែកលើទ្រព្យតែមួយទៅឲ្យម្ចាស់បំណុលច្រើនគ្នាដែលនេះជាចំណុចដែលមានប្រយោជន៍បំផុត នៅក្នុងចំណោមចំណុចជាច្រើនបើប្រៀបធៀបទៅនឹងការធានា។[31] ហើយម្ចាស់បំណុលនីមួយៗមានសិទ្ធិក្នុងការទាមទារឲ្យកូនបំណុលសងប្រាក់តាមលំដាប់។

ហ៊ីប៉ូតែកដែលមានម្ចាស់បំណុលច្រើននាក់ លំដាប់នៃសិទ្ធិរបស់បុគ្គលដែលទទួលផលប្រយោជន៍ពីការចាត់ចែង ត្រូវអនុលោមទៅតាមពេលវេលានៃការចុះបញ្ជីបន្ថែមនៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែក។[32] មានន័យថា ហ៊ីប៉ូតែក ច្រើនបន្តបន្ទាប់គ្នាអាចត្រូវបានបង្កើតនៅលើទ្រព្យតែមួយ ហើយម្ចាស់បំណុលម្នាក់ៗប្រើសិទ្ធិតាមលំដាប់អាទិភាពនៃការចុះបញ្ជីហ៊ីប៉ូតែករបស់ខ្លួន។ ដើម្បីចែកហ៊ីប៉ូតែកតាមលំដាប់ទៅឲ្យម្ចាស់បំណុល គេត្រូវធ្វើតាមលំដាប់នៃការចុះបញ្ជីហ៊ីប៉ូតែករបស់ម្ចាស់បំណុល ចំនុចនេះម្ចាស់បំណុលដែលបានចុះបញ្ជីកាលបរិច្ឆេទមុន នឹងត្រូវទទួលបានសិទ្ធិអាទិភាពយកប្រាក់បំណុលមុនម្ចាស់បំណុលហ៊ីប៉ូតែកដែលបានចុះបញ្ជីក្រោយ។

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់ ឬ ផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកដោយមានការព្រមព្រៀងគ្នាជាមួយម្ចាស់បំណុលផ្សេងទៀត។ ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលបានអនុប្បទាននូវលំដាប់ហ៊ីប៉ូតែក អាចទទួលបាននូវការសង ដោយមានអាទិភាពជាងម្ចាស់បំណុលដែលបានធ្វើអនុប្បទាននូវលំដាប់ហ៊ីប៉ូតែក នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីទឹកប្រាក់ដែលបានពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ត្រឹមកម្រិតនៃទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឲ្យទៅម្ចាស់បំណុលទាំងពីរនោះ។[33]

### ២.៣.៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬ ផលលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួន នៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ពីរ ឆ្នាំ ចុងក្រោយតែប៉ុណ្ណោះ។[34] ប៉ុន្តែក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះប្រាក់ដែលត្រូវបង់សម្រាប់អំឡុងពេល ពីរ ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឲ្យសងសំណងនៃការខូចខាត ដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច។[35] ប៉ុន្តែ

[31] មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[32] មាត្រា ៨៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[33] មាត្រា ៨៦១ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[34] មាត្រា ៨៥២ កថាខណ្ឌទី ១ និងទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[35] មាត្រា ៨៥២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ករណីនេះចំនួនសរុបនៃសំណងការខូចខាតព្រមទាំងប្រាក់ និងធនលាភផ្សេងទៀត មិនអាចលើស ចំនួនសរុបសម្រាប់អំឡុងពេល ពីរ ឆ្នាំបានឡើយ។

បានជាច្បាប់កំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលហ៊ីប៉ូតែក ដទៃផ្សេងទៀតដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីដឹងថាតើតម្លៃនៃអចលនវត្ថុដែលត្រូវបាន យកមកដាក់ជាប្រាតិភោគនោះមានចំនួនប៉ុន្មាន។

## ២.៤. ការអនុវត្ត និងការចាត់ចែងហ៊ីប៉ូតែក

បន្ទាប់ហ៊ីប៉ូតែកត្រូវបានបង្កើត និងមានអនុភាពហើយនោះម្ចាស់បំណុល និងកូនបំណុល ត្រូវមានការអនុវត្តហ៊ីប៉ូតែក(២.៤.១) និង ការចាត់ចែងហ៊ីប៉ូតែក(២.៤.២)។

### ២.៤.១. ការអនុវត្តហ៊ីប៉ូតែក

បើកូនបំណុលពុំបានអនុវត្តនូវកាតព្វកិច្ចទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំឲ្យលក់ ដោយបង្ខំនូវ អចលនវត្ថុហ៊ីប៉ូតែកទៅតុលាការបាន។[36]

បើអ្នកបង្កើតហ៊ីប៉ូតែក មានកម្មសិទ្ធិលើអាគារដែលអ្នកបង្កើតហ៊ីប៉ូតែកនោះ ឬ តតិយជន បានសាងសង់នៅលើហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើតហើយ ម្ចាស់បំណុល ហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកនោះបាន។ ប៉ុន្តែ បើចំនួនថ្លៃ លក់ដី និង អាគារនោះទាបជាងថ្លៃលក់ដីដែលគ្មានអាគារលើនោះម្ចាស់បំណុលអាចទាមទារឲ្យ អ្នកបង្កើតហ៊ីប៉ូតែករុះរើអាគារនោះមុនពេលលក់ដោយបង្ខំ។ ហើយក្នុងករណីដែលតតិយជនមាន កម្មសិទ្ធលើអាគារលើហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រម ជាមួយនឹងដីហ៊ីប៉ូតែកបាន។

តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក អាចក្លាយជាអ្នកទិញក្នុងការលក់ ដោយបង្ខំបាន។ ក្នុងករណី ដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក បានចេញ ចំណាយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សា ឬ ចំណាយបង្កើតតម្លៃ ចំពោះអចលនវត្ថុ ហ៊ីប៉ូតែកនោះ តតិយជននោះអាចទទួលសំណងនៃការចំណាយនោះពីថ្លៃលក់ដោយបង្ខំនូវ អចលនវត្ថុ ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក។

[36] មាត្រា ៨៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២.៤.២. ការចាត់ចែងហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែក អាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជនបានក្នុងករណីនេះហៅថាហ៊ីប៉ូតែកបន្ត។ នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់បាន ត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែកទៅឲ្យ ម្ចាស់បំណុលហ៊ីប៉ូតែក។ ប៉ុន្តែ បើសិទ្ធិលើបំណុលនោះមិនទាន់ដល់កំណត់ពេលត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត គ្រាន់តែអាចទាមទារឲ្យតម្កល់ចំនួនទឹកប្រាក់ ដែលខ្លួនអាចទទួលការសងនោះប៉ុណ្ណោះ។

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀតចំពោះកូនបំណុលតែម្នាក់។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះ បានដោយការព្រមព្រៀងជាមួយម្ចាស់បំណុលផ្សេងទៀត។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុល ហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមអំពីបុគ្គលនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែក ដែលទទួលអនុប្បទាន នូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក ដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ពីប្រាក់ដែលបាន មកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែក ដែលត្រូវចែកឲ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែក ដែលទទួលនូវ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែល បានលះបង់លំដាប់ហ៊ីប៉ូតែកនោះ តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល នៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឲ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែក ដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែក បានតាមការព្រមព្រៀងនោះ។

ការចាត់ចែងហ៊ីប៉ូតែកបន្ត អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក និង អនុប្បទាន ឬ ការបោះបង់ និង ផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែកខាងលើនេះ មិនមានអានុភាពឡើយ បើមិនធ្វើឡើងដោយលិខិតយថាភូតនឹងមិនបានចុះបញ្ជីបន្ថែមអំពីការចាត់ចែងនោះ។ ហើយការកាត់ចែងហ៊ីប៉ូតែក មិនអាចតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងជាអ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះបានឡើយ បើម្ចាស់បំណុលហ៊ីប៉ូតែក មិនបានជូនដំណឹងទៅកូន

បំណុលលែងមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនោះទេ។ បើកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលដំណឹង ឬ ផ្ដល់ការយល់ព្រមនឹងចំនុចខាងលើនេះការសងបានធ្វើឡើងចំពោះអ្នកចាត់ចែងហ៊ីប៉ូតែក ដោយគ្មានការយល់ព្រមពីអ្នកដែលទទួលផលប្រយោជន៍បានឡើយ។ ម្យ៉ាងវិញទៀត បើម្ចាស់បំណុលហ៊ីប៉ូតែកបានចាត់ចែងហ៊ីប៉ូតែកសម្រាប់បុគ្គលច្រើននាក់ លំដាប់នៃសិទ្ធិរបស់បុគ្គលដែលទទួលផលប្រយោជន៍ពីការចាត់ចែងនោះ ត្រូវអនុលោមទៅតាមពេលវេលានៃការចុះបញ្ជីនៅក្នុងបញ្ជីដែលចុះបញ្ជីហ៊ីប៉ូតែកនោះ។

## ២.៥. ការរលត់នៃហ៊ីប៉ូតែក

កិច្ចសន្យាហ៊ីប៉ូតែក នឹងត្រូវបានរលត់ដោយការទាមទារ(២.៥.១) និងការរលត់ដោយអាជ្ញាយុកាល(២.៥.២) ដូចខាងក្រោម។

### ២.៥.១. ការរលត់ដោយការទាមទារ

ក្នុងករណី ដែលតតិយជនដែលទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុភោគចំពោះអចលនវត្ថុហ៊ីប៉ូតែកបានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែកតាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ហើយហ៊ីប៉ូតែកត្រូវរលត់សម្រាប់តតិយជននោះ។ មានន័យថាជាការបញ្ចប់នូវកិច្ចសន្យាហ៊ីប៉ូតែកតាមរយៈការទាមទារអោយបំពេញនូវកាតព្វកិច្ចរបស់កូនបំណុល(២.៥.១.១) និងការសងដោយថ្លៃលក់របស់តតិយជន(២.៥.១.២)។

#### ២.៥.១.១. ការបំពេញនូវកាតព្វកិច្ចរបស់កូនបំណុល

នៅពេលដែលកូនបំណុល បានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននូវក្នុងកិច្ចសន្យាហ៊ីប៉ូតែកហើយ គឺពេលនោះចំណងគតិយុត្តរបស់ពួកគាត់ ត្រូវបានបញ្ចប់អស់ផងដែរ ដោយគ្មាននូវបញ្ហាដែលពាក់ព័ន្ធអ្វីទៀតនោះទេ រវាងម្ចាស់បំណុល និងកូនបំណុល។

#### ២.៥.១.២. ការសងដោយថ្លៃលក់របស់តតិយជន

ក្នុងករណីដែលតតិយជនបានទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ចំពោះអចលនវត្ថុដែលនៅជាប់ហ៊ីប៉ូតែកនោះ គឺតតិយជននោះមានកាតព្វកិច្ចក្នុងការសងថ្លៃលក់ទៅកាន់ម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក។ ក្នុងករណីដែលគាត់បានធ្វើការសងថ្លៃលក់ទៅកាន់ម្ចាស់បំណុលហើយនោះ ការដែលនូវជាប់កាតព្វកិច្ចហ៊ីប៉ូតែកសម្រាប់ តតិ-

យជន គឺត្រូវបានបញ្ចប់។ ប៉ុន្តែបើគាត់នៅបន្តមិនព្រមធ្វើការសងថ្លៃលក់នោះទេ គឺគាត់នូវតែត្រូវតែមានប្រឈមនឹងកាតព្វកិច្ចដែលត្រូវលក់សងនូវទ្រព្យនោះទៅដល់ម្ចាស់បំណុលវហូត ហើយគេអាចធ្វើការប្តឹងទាមទារ រឹបអូសអចលនវត្ថុនោះមកដាក់លក់ដោយបង្ខំបានតាមសេចក្តីសម្រេចរបស់តុលាការ។[37]

### ២.៥.២. ការលក់ដោយអាជ្ញាយុកាល

ហ៊ីប៉ូតែក មិនត្រូវលក់ដោយអាជ្ញាយុកាលចំពោះកូនបំណុលនឹងអ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរត់ព្រមគ្នាទេ។ ពេលដែលបុគ្គល ក្រៅពីកូនបំណុល ឬ ក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែកបានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានលក្ខខណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាល នៃការទទួលសិទ្ធិហ៊ីប៉ូតែកនោះ ត្រូវរលត់។ ប៉ុន្តែចំណុចនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម នូវអចលនវត្ថុហ៊ីប៉ូតែកនោះបានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មថា ហ៊ីប៉ូតែកត្រូវបានបង្កើត លើអចលនវត្ថុនោះ។

## ២.៦.ការបង្កើតហ៊ីប៉ូតែកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី

នៅធនាគារអេស៊ីលីដា ភីអិស៊ី មានប្រតិបត្តិការហិរញ្ញវត្ថុជាច្រើនក្នុងការផ្តល់សេវាឥណ-ទានដល់អតិថិជន។ ហ៊ីប៉ូតែក បានប្រើប្រាស់ជាមធ្យោបាយមួយដ៏សំខាន់ក្នុងការ ទទួលបាននូវប្រាក់កម្ចីរបស់អតិថិជន និងសុវត្ថិភាពនៃទ្រព្យរបស់ម្ចាស់បំណុល។ នៅធនាគារអេស៊ីលីដា ក៏បានយកចិត្តទុកដាក់ និងអនុវត្តយ៉ាងខ្លាំងចំពោះច្បាប់ ដើម្បីធ្វើឲ្យកិច្ចសន្យាមួយមានអនុភាព និងសុពលភាពស្របតាមច្បាប់គឺ ចាំបាច់ណាស់ត្រូវគោរពនូវលក្ខខណ្ឌសុពលភាព (ការព្រមព្រៀងសម្កភាពនៃគូភាគី និងកម្មវត្ថុ)។

### ២.៦.១.ភាគីទទួលយកការបង្កើតហ៊ីប៉ូតែក( ម្ចាស់បំណុល )

ធនាគារ អេស៊ីលីដា មានតំណាងពេញច្បាប់របស់ខ្លួនអាចជា នាយកប្រតិបត្តិ នាយកសាខា ភ្នាក់ងារឥណទាន ឬ មេធាវី គឺអាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ចនៃភូមិសាស្ត្រ សាខា ឬ ទំហំតម្រូវការឥណទានរបស់អតិថិជន។

[37] មាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ចំពោះ ករណីកិច្ច និងសិទ្ធិរបស់ម្ចាស់បំណុល គឺ

- យល់ព្រមទទួលយកការបង្កើតហ៊ីប៉ូតែក
- ផ្តល់ប្រាក់កម្ចី ដល់កូនបំណុលក្នុងករណីដែលលក្ខខណ្ឌផ្សេងៗត្រូវបានបំពេញរួចរាល់
- ត្រួតពិនិត្យនូវការអនុវត្តកិច្ចសន្យារបស់កូនបំណុល
- ក្នុងករណីដែលកូនបំណុល គ្មានលទ្ធភាពសងបំណុលតាមកិច្ចសន្យាខ្ចីប្រាក់ណាមួយ ម្ចាស់បំណុលមានសិទ្ធិប្តឹងទៅអាជ្ញាធរ សមត្ថកិច្ច ឬ តុលាការរឹបអូសទ្រព្យសម្បត្តិដែលបង្កើតហ៊ីប៉ូតែកលក់ឡាយឡុង ដើម្បីទូទាត់សងគ្រប់បំណុលទាំងអស់ រួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឲ្យបានគ្រប់ចំនួន។ ករណីទឹកប្រាក់ទូទាត់សងមិនទាន់គ្រប់ចំនួន ត្រូវតម្រូវឲ្យភាគីកូនបំណុលត្រូវបន្តកាតព្វកិច្ចសងបំណុល ដែលនៅសល់បន្ថែមទៀត រហូតទាល់តែគ្រប់ចំនួន។
- ក្នុងករណីទ្រព្យដែលបង្កើតហ៊ីប៉ូតែកត្រូវបានលក់ ឬ បង្កើតហ៊ីប៉ូតែកបំណុលផ្សេងដោយប្រការណាមួយ ភាគីកូនបំណុលយល់ព្រមទូទាត់គ្រប់បំណុលទាំងអស់ ឲ្យភាគីម្ចាស់បំណុល រួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ទាំងអស់ឲ្យបានគ្រប់ចំនួន ដោយឥតលក្ខខណ្ឌ។

### ២.៦.២.ភាគីបង្កើតហ៊ីប៉ូតែក(កូនបំណុល)

ភាគីនៃកិច្ចសន្យាហ៊ីប៉ូតែក ត្រូវមានៈ

- ទ្រព្យតម្កល់ ធានា ដូចជាវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិអចលនវត្ថុ (ប្លង់រឹង) បង្កាន់ដៃទទួលពាក្យលិខិតផ្ទេរសិទ្ធិកាន់កាប់។
- មានអត្តសញ្ញាណប័ណ្ណ ឬ សៀវភៅគ្រួសារ និងលិខិតស្នាមផ្សេងៗ ឬ អាចមានអ្នកធានា
- មានមុខរបរ អាជីវកម្មស្របច្បាប់។

ករណីកិច្ច និងសិទ្ធិរបស់កូនបំណុលៈ

- ព្រមបង្កើតហ៊ីប៉ូតែកដោយស្ម័គ្រចិត្ត
- ត្រូវអះអាងថា ទ្រព្យសម្បត្តិដែលបង្កើតហ៊ីប៉ូតែកនេះពិតជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ឬ ក្រុមហ៊ុន ដោយពុំមានពាក់ព័ន្ធនឹងបញ្ហាអ្វី ឬ ជនណាមួយដែលធ្វើឲ្យបាត់បង់កាតព្វកិច្ចជាកម្មសិទ្ធិករឡើយ បើផ្ទុយពីនេះខ្លួន ឬ ក្រុមហ៊ុនហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់។

- ធានាមិនចាត់វិធានការណាមួយ ដើម្បីអនុវត្តសិទ្ធិលើទ្រព្យបង្កើតហ៊ីប៉ូតែកដោយធ្វើការដោះដូរ លក់ ផ្ទេរ ហើយសន្យាថែរក្សា ជួសជុល គ្រប់គ្រង ឲ្យបានគង់វង្សល្អរហូតសងបំណុលរួច។
- បើគ្មានលទ្ធភាពសងបំណុលតាមកិច្ចសន្យាខ្ចីប្រាក់ណាមួយ កូនបំណុលសុខចិត្តយល់ព្រមឲ្យម្ចាស់បំណុល ប្ដឹងទៅអាជ្ញាធរ សមត្ថកិច្ច ឬ តុលាការរឹបអូសទ្រព្យសម្បត្តិដែលបង្កើតហ៊ីប៉ូតែកលក់ឡាយឡុង ដើម្បីទូទាត់សងគ្រប់បំណុលទាំងអស់ រួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឲ្យបានគ្រប់ចំនួន។
- ករណីទឹកប្រាក់ទូទាត់សងមិនទាន់គ្រប់ចំនួន កូនបំណុលត្រូវបន្តកាតព្វកិច្ចសងបំណុលដែលនៅសល់បន្ថែមទៀត រហូតទាល់តែគ្រប់ចំនួន។
- ក្នុងករណីទ្រព្យដែលបង្កើតហ៊ីប៉ូតែកត្រូវបានលក់ ឬ បង្កើតហ៊ីប៉ូតែកបំណុលផ្សេងដោយប្រការណាមួយ កូនបំណុលត្រូវទូទាត់គ្រប់បំណុលទាំងអស់ ឲ្យម្ចាស់បំណុល រួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ទាំងអស់ឲ្យបានគ្រប់ចំនួន ដោយឥតលក្ខខណ្ឌ។
- ក្នុងករណីមានការអនុវត្តផ្ទុយ ឬ ដោយរំលោភលើលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ រាល់សោហ៊ុយចំណាយក្នុងការដោះស្រាយលើវិវាទ ជាបន្ទុករបស់ភាគីរំលោភបំពានលើកិច្ចសន្យា។

**២.៦.៣. ការវាយតម្លៃឥណទាន**

ភ្នាក់ងារឥណទានរបស់ធនាគារ ផ្តោតការយកចិត្តទុកដាក់ក្នុងការវាយតម្លៃ ដោយចុះដល់ទីកន្លែង ប្រមូលព័ត៌មាន សិក្សាវិភាគ ដូចចំនុចដូចខាងក្រោមៈ

- វាយតម្លៃអំពីចរិកលក្ខណ: ( Character ) ជាការអង្កេតប្រមូលព័ត៌មានអំពីប្រវត្តិ អត្តចរិត លក្ខណ:សម្បត្តិ សមត្ថភាពគ្រប់គ្រង ជំនាញ បទពិសោធន៍ ទីផ្សារ កេរ្តិ៍ឈ្មោះ ចេតនាសងបំណុល។
- វាយតម្លៃអំពីដើមទុន ( Capital ) ជាការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុក្នុងមុខរបរ ដើមទុន និង ប្រភពទុន។ ការវាយតម្លៃដើមទុន ត្រូវប្រមូលព័ត៌មានអំពីមុខរបរ ដែលជាទិន្នន័យសម្រាប់រៀបចំគម្រោងជំនួញរបស់អតិថិជន ដើម្បីត្រួតពិនិត្យគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចី។
- វាយតម្លៃសមត្ថភាព/លំហូរសាច់ប្រាក់ ( Capacity/Cash flow ) ជាការវាយតម្លៃលំហូរសាច់ប្រាក់របស់អតិថិជន ប្រាក់ចំណូលពីមុខរបរ ( ចំណេញ/ខាត ) និងចំណូលផ្សេងៗប្រចាំថ្ងៃ ប្រចាំខែ រដូវកាល តាមកាល:ទេស:

ឲ្យបានច្បាស់លាស់ ត្រឹមត្រូវ ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការឥណទាន រយៈពេលឥណទាន និងលទ្ធភាពសងប្រាក់។

- វាយតម្លៃទ្រព្យធានា/តម្កល់ធានា ( Collateral ) ការវាយតម្លៃទ្រព្យដាក់ធានា/តម្កល់ធានាសុវត្ថិភាពឥណទាន ត្រូវធ្វើការត្រួតពិនិត្យដល់ទីកន្លែងជាក់ស្តែង។ គេអាចវាយតម្លៃដោយពិចារណាតាម REATOR ដូចខាងក្រោម ៖

- Right collateral : ទ្រព្យសម្បត្តិស្របច្បាប់
- Estimated the value of collateral : តម្លៃប៉ាន់ស្មាននៃទ្រព្យដាក់ធានា
- Ability to sell collateral : លទ្ធភាពដែលអាចលក់ដូរបាន
- Location of collateral : ទីតាំងរបស់ទ្រព្យដាក់តម្កល់
- Type of collateral : ប្រភេទទ្រព្យដាក់តម្កល់
- Ownership : ភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យដាក់តម្កល់
- Risk of collateral : ហានិភ័យនៃទ្រព្យដាក់តម្កល់។

- វាយតម្លៃអំពីលក្ខខណ្ឌ ( Condition ) : គឺជាការធ្វការសិក្សា និង វិភាគអំពីហានិភ័យទាំងឡាយដែលអាចបង្កការជះឥទ្ធិពលដល់ការសងប្រាក់របស់អតិថិជន ដូចជាហានិភ័យលើការគ្រប់គ្រង ហានិភ័យទីផ្សារ ហានិភ័យហរញ្ញវត្ថុ ហានិភ័យទ្រព្យតម្កល់ធានា និង ហានិភ័យលើមុខរបរ។ អាចដាក់លក្ខខណ្ឌបន្ថែមសម្រាប់ធានាសុវត្ថិភាពឥណទាន ដូចជាធ្វើការវាយតម្លៃទ្រព្យសម្បត្តិផ្សេងទៀត។

### ២.៦.៤. កម្មវត្ថុនៃហ៊ីប៉ូតែក

កម្មវត្ថុដែលអាចដាក់ហ៊ីប៉ូតែកបាន ដូចមានចែងនៅក្នុងមាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មានដូចជា អចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ ព្រមទាំងទ្រព្យសម្បត្តិផ្សេងទៀតដែលច្បាប់ពិសេសបានទទួលស្គាល់ (កថាខ័ណ្ឌទី ៣ នៃក្រមដដែល)។

### ២.៦.៥. ហ៊ីប៉ូតែកតូប ឬ ស្តង់

តូប ឬ ស្តង់[38] ជាកន្លែងមួយ ឬជាផ្នែកមួយនៃអាគារដែលសម្រាប់លក់ ឬ ផ្គត់ផ្គង់ទំនិញ និង ផ្តល់សេវាកម្ម ដល់អតិថិជន។

ឧទាហរណ៍₁ លោក ក មានតូបមួយក្នុងផ្សារ ធំថ្មី សម្រាប់ដាក់តាំងលក់ ឬស្តុកទុក ផលិតផលសម្លៀកបំពាក់របស់គាត់ ដើម្បីលក់ដល់អតិថិជន។

ឧទាហរណ៍₂ លោក ខ មានបានជួលស្តង់ មួយនៅក្នុងផ្សារបរវេល ខេត្តបាត់ដំបង សម្រាប់ លក់ផលិតផល កសិកម្ម គ្រឿងសំណង់ និង គ្រឿងបន្លាស់គ្រឿងយន្តមួយចំនួន សម្រាប់តម្រូវការ របស់អតិថិជនរបស់គាត់។

ចំពោះហ៊ីប៉ូតែកតូប ភ្នាក់ងារវាយតម្លៃទ្រព្យ ត្រូវរកឲ្យឃើញពី:

- អត្តសញ្ញាណនៃទ្រព្យ (ជាប្រភេទ ស្តង់ តូប លេខលិខិតកម្មសិទ្ធិ កាលបរិច្ឆេទនៃលិខិត ទ្រព្យត្រូវបានប្រើប្រាស់ និង ម្ចាស់កម្មសិទ្ធិ)
- ភាពត្រឹមត្រូវនៃទ្រព្យ (និរភ័យ ភាពច្បាស់លាស់ ការបង្វិលសាច់ប្រាក់)
- តម្លៃទីផ្សារតម្លៃស្តង់ដារ(កែតម្រូវសម្រាប់កាលៈទេសៈពិសេស និងសម្រាប់ពេលវេលា)
- តម្លៃទ្រព្យវាយតម្លៃ(កែតម្រូវសម្រាប់កត្តាតំបន់)
- តម្លៃទ្រព្យធានា(កែតម្រូវទៅជាទ្រព្យធានា)
- ចំណាត់ថ្នាក់(ការខូចខាតបាត់បង់ ប្រភេទលិខិតកម្មសិទ្ធិ ចំណាត់ថ្នាក់នៃទ្រព្យ)។

[38] Oxford Dictionary of English : Shop

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានបកស្រាយនូវប្រធានបទស្តីពី **ប្រាតិភោគនៅធនាគារ អេស៊ីលីដា ភីអិលស៊ី** រួចមកហើយដោយធ្វើការលើកឡើងពីទ្រឹស្តីនៃការបញ្ចាំ និងការដាក់ហ៊ីប៉ូតែកដែលបានបង្ហាញតាមរយៈបទបញ្ញត្តិច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងធនាគារអេស៊ីលីដា ភីអិលស៊ីផងដែរ។

ការបញ្ចាំ ជាកិច្ចសន្យាប្រាតិភោគមួយដែលមានការនិយមប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ពីព្រោះម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុ ដែលបានទទួលពីកូនបំណុល ឬ តតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុល។ ជាងនេះទៅទៀត ការបញ្ចាំដោយមានការធានា ក៏បានធានានូវសិទ្ធិ និងអានុភាពនៃការឃាត់ទុករបស់ម្ចាស់បំណុល ដោយឡែកធនាគារ អេស៊ីលីដា ក៏បានអនុវត្តដូចគ្នាផងដែរចំពោះការបញ្ចាំ ព្រោះថាវាមានសុវត្ថិភាពក្នុងការផ្តល់នូវឥណទានដល់អតិថិជន និងការសងត្រឡប់មកវិញនៃឥណទាន។ ចំនែកឯហ៊ីប៉ូតែក គឺជាកិច្ចសន្យាប្រាតិភោគមួយប្រភេទដែលមានលក្ខណៈពិសេសខុសពីការបញ្ចាំ ដោយកម្មវត្ថុនៃហ៊ីប៉ូតែកជាអចលនវត្ថុ និងមិនតម្រូវឲ្យកូនបំណុលប្រគល់នូវសិទ្ធិកាន់កាប់អចលនវត្ថុនោះទៅឲ្យម្ចាស់បំណុលនោះទេ ហើយកូនបំណុលក៏មានផលប្រយោជន៍ច្រើនបើប្រៀបធៀបនឹងការបញ្ចាំ ដោយកូនបំណុលអាចបង្កើតសិទ្ធិហ៊ីប៉ូតែកលើទ្រព្យសម្បត្តិតែមួយរបស់ខ្លួន ឲ្យម្ចាស់បំណុលច្រើននាក់បាន ហើយម្ចាស់បំណុលក៏មានសិទ្ធិទទួលបាននូវសំណងទៅតាមលំដាប់ហ៊ីប៉ូតែកផងដែរ។

ទន្ទឹមនឹងផងនេះដែរ ចំពោះការអនុវត្តនូវគោលការណ៍នៃការបង្កើតហ៊ីប៉ូតែកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី មានលក្ខណៈខុសពីច្បាប់បានកំណត់នៅចំណុចមួយចំនួន ដែលច្បាប់បានកំណត់ផ្តល់សិទ្ធិឲ្យកូនបំណុលហ៊ីប៉ូតែកមានសិទ្ធិរក្សាទុកនូវប័ណ្ណកម្មសិទ្ធិ(ប្លង់អចលនវត្ថុ) និងអាចយកប័ណ្ណកម្មសិទ្ធិនោះទៅដាក់ហ៊ីប៉ូតែកបានជាមួយម្ចាស់បំណុលផ្សេងទៀតបាន ពោលគឺចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់។ ប៉ុន្តែការអនុវត្តផ្ទាល់ ការបង្កើតហ៊ីប៉ូតែកនៅធនាគារអេស៊ីលីដា ភីអិលស៊ី គឺបន្ទាប់ពីចុះកិច្ចសន្យាហ៊ីប៉ូតែករួចហើយ ភាគីកូនបំណុលត្រូវធ្វើពាក្យស្នើរសុំការរក្សាទុកប័ណ្ណកម្មសិទ្ធិនៅធនាគារដើម្បីការពារហានិភ័យដោយប្រការណាមួយ ជាហេតុដែលធ្វើឲ្យកូនបំណុលបាត់បង់នូវប្រយោជន៍ ក្នុងការប្រើប្រាស់សិទ្ធិហ៊ីប៉ូតែកតាមច្បាប់បានកំណត់។ ចំនែកឯការប្រាក់វិញក៏ស្ថិតនូវកម្រិតមួយដែលខ្ពស់ និងគោលការណ៍នៃការផ្តល់ឥណទានមានភាពស្មុកស្មាញ ដែលមានច្រើន

ដំណាក់កាលដែលធ្វើឲ្យប្រជាពលរដ្ឋគិតថាពិបាក និងបានស្វែងរកសេវាឥណទានណាដែលឆាប់រហ័សជាង ទោះជាអត្រាការប្រាក់ខ្ពស់ជាងធនាគារក៏ដោយ ដូចជាខ្ចីប្រាក់ពីអ្នកចងការប្រាក់តាមផ្ទះ កន្លែងបញ្ចាំតូចៗ(ប្រាតិភោគដោយអនុប្បទាន) ឬ ក៏ខ្ចីពីបងប្អូនសាច់ញ្ញាតិ។

ទន្ទឹមនឹងបញ្ហាដែលជាចំនុចខ្វះខាត ធនាគារអេស៊ីលីដា ភីអិលស៊ី គួរតែផ្តល់នូវព័ត៌មានលម្អិត ច្បាស់លាស់ និងផ្តល់ភាពងាយស្រួល និងជួយសម្រួលក្នុងដំណើរការនីតិវិធីក្នុងការទទួលបានឥណទានដល់អតិថិជនដើម្បីជៀសវាងការភាន់ច្រលំផ្សេងៗ ក្នុងប្រតិបត្តិការនៃការឥណទាន និងជាការទាក់ទាញអតិថិជន។ ជាងនេះទៀតធនាគារត្រូវជ្រើសរើសភ្នាក់ងារឥណទានដែលមានចំនេះដឹងផ្នែកច្បាប់កិច្ចសន្យា ដោយជៀសវាងការពន្យល់អំពីលក្ខខណ្ឌ និងគោលការណ៍មិនច្បាស់ និងគ្រប់ជ្រុងជ្រោយដល់អតិថិជន ជាហេតុធ្វើឲ្យមានការភាន់ច្រឡំទៅលើផ្នែកណាមួយនៃកិច្ចសន្យាដែលនាំឲ្យកិច្ចសន្យានោះក្លាយជាមោឃៈបាន។ បន្ថែមលើនេះទៀតធនាគារ គួរតែអនុវត្តតាមបទបញ្ញត្តិដែលច្បាប់បានកំណត់ ដើម្បីជាផលប្រយោជន៍នៃភាគីទាំងសងខាង និងជៀសវាងនូវវិវាទផ្សេងៗដែលកើតឡើង។ បន្ថែមលើនេះទៀតធនាគារគួរតែ បន្ធូរបន្ថយអត្រាការប្រាក់ដែលសមរម្យមួយដែលអាចទទួលយកបានទាងសងខាងដើម្បីសម្រួលដល់ប្រជាពលរដ្ឋក្រីក្រ អាចមានលទ្ធភាពក្នុងការប្រើប្រាស់សេវាឥណទានរបស់ធនាគារ។

ក្នុងក្តីសង្ឃឹមនាពេលអនាគត គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលមានប្រតិបត្តិការជាប្រាក់កម្ចីដែលមានការទាក់ទងនឹងប្រាតិភោគ ពិតជាខិតខំស្វែងរកយន្តការសម្របសម្រួលផ្សេងៗទាំងឡាយ ដើម្បីជៀសវាងការដកទុកប័ណ្ណកម្មសិទ្ធិពីកូនបំណុល។ នៅពេលស្ថាប័នផ្តល់ប្រាក់កម្ចីបានអនុវត្តតាមគោលការណ៍ច្បាប់ នោះអតិថិជនដែលជាកូនបំណុល ពិតជាស្រឡះចិត្ត រីករាយ និងកាន់តែមានទំនាក់ទំនងជាមួយ គ្រឹះស្ថានហិរញ្ញប្បទានទាំងនោះ កាន់តែទ្វេឡើងៗជាក់ជាមិនខាន ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ដល់ភាគីទាំងសងខាងទាំងម្ចាស់បំណុល និងកូនបំណុល។

# ឯកសារពិគ្រោះ


១. ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

២. សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី។

៣. ច្បាប់ភូមិបាល ឆ្នាំ ២០០១។

៤. ច្បាប់ស្តីពីកិច្ចប្រតិបត្តិការណ៍ដែលមានការធានា។

៥. សៀវភៅសិក្សាស្តីពី នីតិប្រាតិភោគ របស់លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០០៦

៦. ឯកសារធនាគារអេស៊ីលីដាស្តីពី គោលការណ៍ប្រតិបត្តិឥណទាន ខ្នាតតូចបំផុត និងខ្នាតតូច

៧. បទបង្ហាញពីសេវាឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

៨. គេហទំព័ររបស់ធនាគារអេស៊ីលីដា ភីអិលស៊ី www.acledabank.com.kh/kh/eng/index.php

# តារាងបញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**:

- ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា។
- លិខិតប្រកាសរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។
- លិខិតប្រកាសរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ។
- លិខិតប្រកាសរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ឧបសម្ព័ន្ធទី២**:

- ប្រកាសរបស់ធនាគារជាតិ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ចេញផ្សាយលេខ ធ៧ ០៩ ២១៣ ប្រ ក ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩។
- ប្រកាសរបស់ក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ ១២៨ កយ.ប្រ ក ១១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១។
- ប្រកាសរបស់ធនាគារជាតិស្តីពីការកំណត់អត្រាការប្រាក់ ចេញផ្សាយលេខ ធ៥ ៩៥៤៧ ប្រ ក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៥។

**ឧបសម្ព័ន្ធទី៣**:

- គំរូពាក្យសុំចុះឈ្មោះ ខ្ចីប្រាក់
- គំរូពាក្យចុះឈ្មោះ ស្នើសុំឥណទាន
- គំរូពាក្យស្នើសុំឥណទាន

**ឧបសម្ព័ន្ធទី៤**:

- គំរូកិច្ចសន្យា ខ្ចីប្រាក់
- គំរូកិច្ចសន្យា ដាក់បញ្ចាំ
- គំរូកិច្ចសន្យា ដាក់ធានាសន្និធិ

-

**ឧបសម្ព័ន្ធទី៥**:

- គម្រោងជំនួញ
- ទម្រង់សម្ភាសន៍
- ទម្រង់វាយតម្លៃទ្រព្យដាក់ធានា ប្រភេទជាអចលនទ្រព្យ
- កំណាត់ហេតុវាយតម្លៃទ្រព្យដាក់ធានា

**ឧបសម្ព័ន្ធទី៦**:

- កិច្ចសន្យានៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- គំរូពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក
- គំរូកិច្ចសន្យាបង្កើតហ៊ីប៉ូតែក
- គំរូកិច្ចសន្យាបង្កើតហ៊ីប៉ូតែកគួប

**ឧបសម្ព័ន្ធទី៧**:

- ពាក្យស្នើរសុំរក្សាទុកលិខិតសម្គាល់កម្មសិទ្ធិនៅធនាគារ

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធទី៣

# ឧបសម្ព័ន្ធទី៤

# ឧបសម្ព័ន្ធទី៥

# ឧបសម្ព័ន្ធទី៦

# ឧបសម្ព័ន្ធទី៧

# សេចក្តីផ្តើម

# ជំពូក ១

# ការបញ្ចប់

# ជំពូក ២

# ហ៊ីប៉ូតែក

# សេចក្តីសន្និដ្ឋាន

# ឯកសារយោង

# តារាងបញ្ជីឧបសម្ព័ន្ធ